ព្រឹត្តិបត្រ មត៌កខ្មែរ
Morodok Khmer

លេខ ០៤ ឆ្នាំទី ០១ ខែមិថុនា គ.ស. ២០១០ - ព.ស. ២៥៥៤

# ទឹម សាខន ពីអ្នកស្ម័គ្រចិត្តការពារសិទ្ធិខ្មែរក្រោម ក្លាយទៅជាបុរសនៃប្រវត្តិសាស្ត្រ




## ជីវប្រវត្តិសង្ខេប ព្រះតេជគុណ ទឹម សាខន

| មាតិការឿង | ទំព័រ |
|---|---|


• ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តយួន........០៤
• បុណ្យវិសាខបូជានៅវត្ត...................០៦
• ដើម្បីផលប្រយោជន៍ជាតិ................០៨
• ឯកឧត្តមសម រង្ស៊ីជួបសំណេះ..........៩
• ព្រះមហាប្រសិទ្ធិវិរៈកាន់ ទទួល.....១២
• ឧបករណ៍ភ្លេងខ្មែរ..........................១៣
• ជីវប្រវត្តិសង្ខេបនិងការតស៊ូ............១៧
• អាជ្ញាធរនៅមណ្ឌលគិរី....................១៨
• លោកអូបាម៉ាបង្ហាញឱ្យ..................២៣
• ការស្រាវជ្រាវនៅអូស្ត្រាលី..............២៦
• កុំចេះតែចង់ គ្មានឫង់កុំទៅ.............៣០


មានកំណើតជាខ្មែរក្រោម នៅខេត្តមាត់ជ្រូក ជាខេត្តមួយជាប់ព្រំដែននឹងខេត្តតាកែវ នៃប្រទេសកម្ពុជា។

ជីវិតតាំងពីកុមារដល់ធំដឹងក្តីជួបតែសង្គ្រាមរាំងដល់ រវាងទាហានខ្មែរក្រហម និងកងទ័ពយួនក្នុងសម័យមួយ ដែលប្រទេសកម្ពុជាឋិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ដែនដីកម្ពុជាក្រោមឋិតនៅក្រោមអាណានិគមរដ្ឋាភិបាលបក្សកុម្មុយនិស្តយួន។ លោក **ទឹម សាខន** ខ្សែជីវិតជួបតែការគំរាមកំហែង ការជំលៀសនិងការរឹបយក ផ្ទះ សម្បែង ដីកេរដូនតាពីសំណាក់ទាហានខ្មែរនិងយួននៅតាមបណ្តោយព្រំដែន។ ដោយធ្លាប់ជាជនរងគ្រោះម្នាក់ ត្រូវបានខ្មែរក្រហមកៀរពីមាត់ជ្រូកឲ្យទៅរស់នៅៗភូមិភ្នំខិន ខេត្តតាកែវនោះ ក្រោយមកលោកក៏បានបួសជាសង្ឃ ហើយតែងតែសង្គ្រោះនិងផ្តល់ជម្រកដល់ខ្មែរក្រោម.....*(តទៅទំព័រទី៧)*

**វត្តខេមររង្សី ក្រុងសាន់ហូសេ**
1594 Cunningham Ave San Jose, CA 95122
Tel: (408) 923-2166 / 550-5060
http://www.unitedkhmerkrom.org

# លិខិតអញ្ជើញ

ដើម្បីបានជួបសំណេះសំណាលផ្ទាល់ ជាមួយនឹងព្រះតេជគុណ **ទឹម សាខន** អតីត ព្រះចៅអធិការវត្តភ្នំដិន ខាងជើង ស្រុកគិរីវង្ស ខេត្រតាកែវ, ព្រះតេជគុណ **យ៉ាញ តូន** និងព្រះតេជគុណ **គឹម មឿន** អតីតសមណនិស្សិតសាលាបាលីជាន់ខ្ពស់ នៅដែនដីកម្ពុជាក្រោម យើងខ្ញុំ ព្រះករុណា អាត្មាភាព ជាគណៈកម្មការ និងអាចារ្យ **វត្តខេមររង្សី** ទីក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រញ៉ា ផ្តើមរៀបចំពិធីបុណ្យអបអរសាទរ ចំពោះវត្តមាន អតីតសង្ឃ ទាំងបីព្រះអង្គ ដែលបានសាងផ្នួសឡើងវិញ បន្ទាប់ពីអាជ្ញាធរយៀកណាម ដោះលែងចេញពីពន្ធនាគារ កាលពីឆ្នាំ២០០៨។

អាស្រ័យហេតុនេះ យើងខ្ញុំសូមគោរពអញ្ជើញ លោក លោកស្រី និងបងប្អូនជនរួមជាតិជិតឆ្ងាយ មេត្តាចូលរួមឱ្យបានច្រើនកុះករ ដើម្បីស្តាប់នូវថេរដិកា របស់អ្នកទោសគ្មានកំហុសទាំងបីព្រះអង្គ ជុំវិញអាថ៌កំបាំងក្នុងគុក នៃប្រទេសយៀកណាម និងស្ថានភាព ព្រះពុទ្ធសាសនាខ្មែរ នៅកម្ពុជាក្រោម។

On behalf of the Buddhist monks and committee members of Wat Khemara Rangsey, we would like to invite you, your families and friends, to attend our special event to welcoming **Ven. Tim Sakhorn, Ven. Danh Tol, and Ven. Kim Moul,** who were arrested, defrocked, and imprisoned in Vietnam in 2007, coming to San Jose on Saturday, June 19, 2010, at Wat Khemara Rangsey.

From 8:30 a.m. — 12:00 p.m. Buddhist ceremony. From 12:00 p.m.— 1:00 p.m. Lunch. From 1:00 — 4:00 p.m. **Ven. Tim Sakhorn, Ven. Danh Tol, and Ven. Kim Moul** will tell their stories and experiences about their brave journey to seek for the religious freedom for the Khmer-Krom in Kampuchea-Krom.

## កម្មវិធីបុណ្យ

## ថ្ងៃសៅរ៍ ទី ១៩ ខែមិថុនា ឆ្នាំ២០១០ (Saturday, June 19, 2010)

-ពីម៉ោង **8:30AM -12:00PM** ជួបជុំពុទ្ធបរិស័ទប្រារព្ធសាសនកិច្ច, និមន្តព្រះសង្ឃទ្រង់បិណ្ឌបាត្រ, វេរភត្តប្រគេនព្រះសង្ឃ និងដារបង្សុកូលឧទ្ទិសកុសលជូនវីរជនស្នេហាជាតិគ្រប់ជំនាន់ និងបុព្វការីជន មានមាតាបិតាជាដើម។

-ពីម៉ោង **12:00PM – 1:00PM** អញ្ជើញលោក លោកស្រី ទទួលភោជនាហារ។

-ពីម៉ោង **1:00PM - 4:00PM** ពិធីសំណេះសំណាលផ្ទាល់ជាមួយ ព្រះតេជគុណ **ទឹម សាខន**, ព្រះតេជគុណ **យ៉ាញ តូន** និង ព្រះតេជគុណ **គឹម មឿន** រួមទាំងមន្ត្រីជាន់ខ្ពស់ សហព័ន្ធខ្មែរកម្ពុជាក្រោម។

***សូមអរគុណ!***

# មូលហេតុ

## ស្តីពីការចេញផ្សាយ នៃព្រឹត្តិប័ត្រ មត៌កខ្មែរ

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** នៃពុទ្ធិកសមាគមខ្មែរក្រោម វត្តខេមររង្សី នៅទីក្រុងសាន់ហូសេ្ស នឹងចេញផ្សាយតាមគេហទំព័រ http://www.unitedkhmerkrom.org / http://morodokkhmer2010.wordpress.com និងបោះពុម្ពផ្សាយជារៀងរាល់ខែ ដើម្បីពង្រឹងពង្រីក វិស័យវប្បធម៌, ប្រពៃណី, ទំនៀមទម្លាប់, ភាសា, អក្សរសាស្ត្រជាតិ និងដំណឹងថ្មីៗ ពីសហគមន៍ខ្មែរ នៅក្នុងនិងក្រៅប្រទេស។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ផ្សព្វផ្សាយនូវសកម្មភាពសង្គម, ព័ត៌មានខ្មែរ-អន្តរជាតិ, អប់រំ, សុខភាព, កីឡា, រឿងរ៉ាវប្លែកៗ, សីលធម៌, ទស្សនៈកវី និងពុទ្ធសាសនាជាដើម....។ល។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** យកប្រាសាទព្រះវិហារធ្វើជាសញ្ញា (Logo) ដោយប្រាសាទព្រះវិហារ គឺជាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ហើយអង្គការយូនីស្កូ បានចុះក្នុងបញ្ជីបេតិកភ័ណ្ឌពិភពលោក កាលពីថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០០៨ នៅទីក្រុងកេប៊ិច ប្រទេសកាណាដា។

ព្រឹត្តិប័ត្រ **មត៌កខ្មែរ** ចេញផ្សាយជារៀងរាល់ខែ តាមគេហទំព័រ និងបោះពុម្ពចែកចាយដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០ នេះតទៅ។

សេចក្តីដូចបានប្រគេន-ជំរាបជូនដំណឹងខាងលើ សូមមិត្តអ្នកអាននៅក្នុងនិងក្រៅប្រទេស ជាពិសេសសហគមន៍ខ្មែរ នៅទីក្រុងសាន់ហូសេ្ស មេត្តាជ្រាបជាព័ត៌មាន និងគាំទ្រនូវដំណឹងថ្មីៗ ពីព្រឹត្តិប័ត្រ **មត៌កខ្មែរ** ដោយសោមនស្សរីករាយ។

*បញ្ជាក់៖ លោក លោកស្រី ចង់ផ្សាយពាណិជ្ជកម្មជាមួយ ព្រឹត្តិប័ត្រ មត៌កខ្មែរ សូមទំនាក់ទំនង* Tel: **(408) 923-2166**

ធ្វើនៅទីក្រុងសាន់ហូសេ្ស, ថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០១០

គណៈកម្មការ **ព្រឹត្តិប័ត្រ មត៌កខ្មែរ**

---

## ព្រឹត្តិប័ត្រមត៌កខ្មែរ

- ព្រះតេគុណ សឹង យ៉ឹង រតនា នាយកការផ្សាយ
- ព្រះតេជគុណ ថាច់ សុរិយា និពន្ធនាយក
- លោក អ៊ុក សុភ័ព្វ សម្រួលអត្ថបទ
- អ្នកស្រី គីលីន វីនីតា ពាណិជ្ជកម្ម
- លោក កោះ ថុន ពិនិត្យអត្ថបទ
- អ្នកស្រី បៃ សុផានី ផ្សព្វផ្សាយ
- លោក នឹង ស៊ិន ទីប្រឹក្សា

## អាសយដ្ឋានទំនាក់ទំនង

**ព្រឹត្តិប័ត្រ មត៌កខ្មែរ**

**MORODOK KHMER**

1594 Cunningham Ave.

San Jose, CA 95122. U.S.A

E-mail: morodokkhmer2010@gmail.com

Tel: (408) 923-2166/890-8877/550-5050

http://www.unitedkhmerkrom.org

# ថ្នាក់ដឹកនាំបក្សកុម្មុយនិស្តយួន គួរតែឈប់ដើរគំរាមពលរដ្ឋខ្មែរក្រោម

មេដឹកនាំ និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃប្រទេសយួនគ្មានគំនិតឧស្សាហ៍ចុះទៅសួរសុខទុក្ខពលរដ្ឋដោយសុទ្ធចិត្តឡើយ ជាពិសេសដំណើរចុះទៅជួបពលរដ្ឋខ្មែរក្រោម ។ ក្រៅពីកាតព្វកិច្ចទាំងឡាយដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម គ្រប់ស្ថាប័នទាំងអស់ ត្រូវតែតស៊ូប្តូរផ្តាច់អស់ពីកម្លាំងកាយកម្លាំងចិត្តទំនុកបំរុងនូវអ្វីៗគ្រប់យ៉ាងដែលពលរដ្ឋកំពុងតែខ្វះខាតឬត្រូវការ ទំនាក់ទំនងយ៉ាងជិតស្និទជាមួយប្រជារាស្ត្រយកចិត្តស្តាប់មតិ យោបល់ និងទទួលយកការត្រួតពិនិត្យ រិះគន់ពីប្រជារាស្ត្រ ពង្រីកសង្គមនិយមប្រជាធិបតេយ្យ។ល។(ជំពូកមោត្រា៨ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម)។ ផ្ទុយពីនេះ ថ្នាក់ដឹកនាំក្នុងជួររដ្ឋាភិបាលនិងបក្សកុម្មុយនិស្តយួន ព្រមទាំងក្រុមតំណាងរាស្ត្រទាំងនោះ ឆ្លៀតយកឱកាសនេះទៅគំរាមប្រជារាស្ត្រខ្មែរក្រោមទៅវិញ។

បើប្រសិនជារដ្ឋាភិបាលយួន ចេះមានចិត្តឈឺឆ្អាលដល់ជីវភាពរស់នៅ ទុក្ខលំបាករបស់ប្រជារាស្ត្រខ្មែរក្រោមពិតប្រាកដមែន គេគួរតែចុះទៅសិក្សាអំពីស្ថានភាពសង្គមរបស់ខ្មែរក្រោម ក្នុងរដូវដែលខ្មែរក្រោមកំពុងតែមមាញឹក កំពុងតែខ្វល់ខ្វាយនឹងការងារស្រែចំការជួញដូរ។ល។ដើម្បីទទួលបានទិន្នន័យស្តីអំពីទុក្ខលំបាកនិង សេចក្តីត្រូវការរបស់ប្រជារាស្ត្រខ្មែរក្រោមនោះទើបជាការត្រឹមត្រូវ គួរតែអាជ្ញាធរយួនចុះទៅសិក្សាអំពីផលដំណាំ ចិញ្ចឹមសត្វ និងមុខរបររកស៊ីផ្សេងៗដែលប្រជារាស្ត្រខ្មែរក្រោមត្អូញត្អែរថា ទទួលរងនូវការខាតបង់នោះ គួរតែអាជ្ញាធរយួនចុះទៅស្វែងយល់ពីភាពក្រីក្ររបស់ប្រជាពលរដ្ឋខ្មែរក្រោម កុមារខ្មែរក្រោម កើតឡាក្បុ កុមារខ្មែរក្រោមអនក្ខរកម្ម ជនពិការ ជនចាស់ជរាខ្មែរក្រោមខ្វះទីពឹង ខ្មែរក្រោមជាជនរងគ្រោះក្នុងសកម្មភាពរំលោភដីធ្លី ។ល។ ប្រសិនបើអាជ្ញាធរយួនមានចិត្តឈឺឆ្អាល នឹងស្ថានភាពរបស់ខ្មែរក្រោមពិតប្រាកដមែននោះ គួរតែតាំងចិត្តក្លាហានចុះទៅបើកវេទិកាសាធារណៈជាអចិន្ត្រៃយ៍នៅគ្រប់ដំបន់ទាំងអស់ ដើម្បីផ្តល់ឱកាសដល់ប្រជារាស្ត្រទូទៅនៅគ្រប់មជ្ឈដ្ឋានសម្តែងមតិយោបល់ ហ៊ានបកអាក្រាត នូវភាពទុក្ខលំបាករបស់ខ្លួននិងការគាបសង្កត់ពីអាជ្ញាធរមូលដ្ឋាន ការរំលោភដីធ្លី ពីសំណាក់អាជ្ញាធរមូលដ្ឋាន ការរំលោភបំពានមកលើសេរីភាពក្នុងការប្រតិបត្តិជំនឿព្រះពុទ្ធសាសនា វប្បធម៌ ប្រពៃណីជាតិរបស់ខ្លួន សម្តែងបង្ហាញនូវការខ្វះខាតអំពីការគ្រប់គ្រងរបស់អាជ្ញាធរមូលដ្ឋាន និង អសមត្ថភាពក្នុងការធានានូវរាល់សេរីភាពជាមូលដ្ឋានរបស់ប្រជារាស្ត្រខ្មែរក្រោម ដែលមានមកពីកំណើតអស់ទាំងនោះ ព្រមទាំងសេរីភាពគ្រប់យ៉ាង ដែលប្រជារាស្ត្រត្រូវទទួលបានដូចដែលមានចែង នៅក្នុងរដ្ឋធម្មនុញ្ញប្រទេសយួនខ្លះនោះ ក្រៅពីនោះ អាជ្ញាធរយួនត្រូវហ៊ានផ្តល់ឱកាសទាំងនោះ ឲ្យប្រជារាស្ត្រខ្មែរក្រោមក៏ដូចជាប្រជារាស្ត្រទូទៅទាមទារឲ្យអាជ្ញាធរប្រគល់មកវិញនូវរាល់សិទ្ធិទាំងឡាយដែលអាជ្ញាធរបានតាំងពីអតីតរហូតមកដល់បច្ចុប្បន្ននោះ។ល។

ក៏ប៉ុន្តែមិនដូច្នោះឡើយ ថ្នាក់ដឹកនាំកំពូលៗរបស់រដ្ឋាភិបាលយួនបែរជាឆ្លៀតយកឱកាសចុះមកជួបព្រះសង្ឃ និង ប្រជារាស្ត្រខ្មែរក្រោមមួយចំនួននៅតាមវត្តអារាមក្នុងរដូវបុណ្យទានផ្សេងៗ។ ដូចជានៅក្នុងឱកាសបុណ្យភ្ជុំបិណ្ឌនិងបុណ្យសែនដូនតាប្រចាំឆ្នាំ ស្រាប់ហើយសកម្មភាពនៃដំណើរចុះទៅជួបនោះ បានត្រឹមតែចែកកញ្ចប់អំណោយបន្តិចបន្តួច ជូនពរ និងលើកតំកើងអួតសរសើរគុណសម្បត្តិបក្ស និងរដ្ឋាភិបាលរបស់គេតែប៉ុណ្ណោះ។ ជាពិសេសគឺ ការញុះញង់ឲ្យប្រជារាស្ត្រខ្មែរក្រោម គោរពយកនូវរាល់វិធានការនយោបាយរបស់បក្សកុម្មុយនិស្ត និងរដ្ឋាភិបាលគេ ដែលជាគោលនយោបាយ ដែលអ្នកប្រជាធិបតេយ្យខ្មែរក្រោម នៅក្នុងនិងក្រៅប្រទេសយល់ថាជាការ ***(តទៅទំព័រទី១៦)***




# ហាងខ្មែរលក់មាស ឡាក់គី

# LUCKY JEWELRY

- មានលក់ពេជ្រ **HRD, GIA, IGI** គ្រប់មូដ
- មាសសន្លឹក 24K 999, Canada Credit Swiss
- គ្រឿងត្បូង South - Sea Pearl គ្រប់ជំពូក
- មានគ្រឿងអលង្ការនាំចូលថ្មីៗពីបរទេស
- មានរចនាមូដល្អៗទាន់សម័យនិយម
- ទិញចូលមានតម្លៃខ្ពស់
- លក់ចេញមានតម្លៃថោកសមរម្យ
- សូមអញ្ជើញអតិថិជនចូលដារដោយមេត្រីភាព



- There are vast choices of models for HRD, GIA, IGI diamonds.

* 24K ... 999 flat-carded gold's are available from Canada Credit Swiss.
* All kind availabilities for gems and pearls from South-Sea Pearl.
* Newly imported jewelries from international countries.
* Modernize models are always updated.
* We buy your jewelries with high value offerings.
* We sell our jewelries with low, affordable pricing.
* **Please stop by, and we will guarantee your satisfaction**!

- **ម៉ោងធ្វើការ៖** Mon - Fri: 10:00am - 7:00pm

Tel: (408) 238-2098

- **2471 Alvin Ave. San Jose, CA 95121**

មានទទួល Visa, Master Card ៣ខែមិនគិតថ្លៃចុងការ

# មជ្ឈមណ្ឌលខ្មែរថែរក្សាភ្នែក SUNRISE

## Sunrise Medical-Dental Center

- មានវេជ្ជបណ្ឌិតស្ទាត់ជំនាញក្នុងការពិនិត្យភ្នែក។
- មានម៉ាស៊ីនទំនើបអាចវាស់ភ្នែកនិងកាត់កញ្ចក់វ៉ែនតា តាមតំរូវការ។
- មានវេជ្ជបណ្ឌិតនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ។




Phone: (408) 227-6444
Fax: (408) 227-5056
www.kasod.com

DR. KENNETH A. WIENER
DR. STEVEN M. KAS
Optometrists

Eye Care/Lasik Consultations

Sunrise Medical-Dental Center
5710 Cahalan Avenue, Bldg. 2 San Jose, CA 95123

5710 Cahalan Avenue, Bldg.2
San Jose, CA 95123
Phone: (408) 227-6444
Fax: (408) 227-5056
www. Kasod.com

# បុណ្យវិសាខបូជានៅវត្តខេមររង្សី ក្រុងសាន់ហ្វូស្សេ

កាលពីថ្ងៃទី៨-៩ខែឧសភា ឆ្នាំ២០១០កន្លងទៅហើយនេះ នៅវត្តខេមររង្សី ក្រុងសាន់ហ្វូស្សេ រដ្ឋកាលីហ្វ័រញ៉ា បានរៀបចំប្រារព្ធពិធីបុណ្យវិសាខបូជា ដើម្បីរំលឹកនឹកដល់ថ្ងៃនក្ខត្តឫក្សទាំងបី គឺថ្ងៃដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទ្រង់ប្រសូតិ, ទ្រង់ត្រាស់ដឹង និងយាងចូលកាន់បរិនិព្វាន និងពិធីទទួលព្រះអដ្ឋិធាតុនៃសាវកព្រះពុទ្ធទាំងបីព្រះអង្គគឺ ព្រះមហាមោគ្គល្លាន, ព្រះមហាសារីបុត្រ, ព្រះសិម្ពលីថេរ ពីអ្នកស្រី **គឹម វណ្ណី** អញ្ជើញ



*ព្រះតេជគុណគីរីសុវណ្ណ ថាច់ ធឿងនិងព្រះតេជគុណច័ន្ទ សុផាត សំដែងព្រះធម៌ទេសនា ក្នុងពិធីបុណ្យវិសាខបូជា វត្តខេមររង្សី*

មកពីរដ្ឋ Missouri ដើម្បីតម្កល់ទុកក្នុងវត្តខេមររង្សី សំរាប់ពុទ្ធបរិស័ទធ្វើសក្ការៈបូជានិងជាតំណាងព្រះពុទ្ធសាសនាជាដើម។

នៅក្នុងកម្មវិធីបុណ្យនេះដែរ ដោយមានការនិមន្តចូលរួមក្រោមអធិបតីភាពពីសំណាក់ព្រះតេជគុណកាន់ សុផាន់ណារិទ្ធិ,ព្រះអង្គច័ន្ទ សុផាននិមន្តមកពីប្រទេសកម្ពុជា,ព្រះតេជគុណ **គីរីសុវណ្ណ** ថាច់ ធឿង ព្រះចៅអធិការវត្តវេឡុវ័ន ទីក្រុង Mobil រដ្ឋ Alabama ព្រះតេជគុណ **ខេមនន្ទោ** គឹម ស៊ី វុឌ្ឍី រដ្ឋ Minnesota និងព្រះសង្ឃនៅម្តុំក្រុងសាន់ហ្វូស្សេផងដែរ។

ព្រះសង្ឃនិងគណៈកម្មការវត្តខេមររង្សី បានរៀបកម្មវិធីបុណ្យទៅតាមប្រពៃណីព្រះពុទ្ធសាសនា មានធ្វើពិធីសក្ការៈបូជនីយដ្ឋានទាំង៣ នមស្សការ សមាទានសីល ចំរើនព្រះបរិត្ត ពុទ្ធាភិសេក រហូតដល់ពេលព្រឹកនិមន្តព្រះសង្ឃទ្រង់បិណ្ឌបាត្រ ហើយវេរភត្តាហារ និង



*ព្រះសង្ឃ និងពុទ្ធបរិស័ទធ្វើពិធីនមស្សការព្រះសារីរិកធាតុ*

អារធនាព្រះធម្មិកាចារ្យទាំងពីរព្រះអង្គ គឺព្រះមហាថេរ **គីរីសុវណ្ណ** ថាច់ ធឿន និងព្រះអនុថេរ ច័ន្ទ សុផាត សំដែងព្រះធម៌ទេសនាតាមបែបសង្គាយនាត្រៃពីរ ស្តីអំពីបុណ្យវិសាខបូជា។ មិនតែប៉ុណ្ណោះព្រះធម្មិកាចារ្យទាំងពីរអង្គ បានចោទសួរសំណួរទាក់ទងទៅនឹងព្រះពុទ្ធសាសនារុងរឿងដោយសារពុទ្ធបរិស័ទទាំងបួនជំពូក ដើម្បីលើកយកមកអត្ថាធិប្បាយជូនដល់លោកយាយ លោកតាទាំងអស់ បានយល់ពីខ្លឹមសារនិងអត្ថន័យទាំងនោះ ថាតើពុទ្ធបរិស័ទទាំងបួនជំពូកនោះជានរណា? ហើយមានតួនាទីអ្វីខ្លះក្នុងការថែរក្សាខឿនវប្បធម៌ជាតិ សាសនាព្រះពុទ្ធឱ្យគ្រប់៥០០០ព្រះវស្សា។ពុទ្ធបរិស័ទទាំង៤ជំពូកនោះគឺភិក្ខុ សាមណេរ ឧបាសក ឧបាសិកាអ្នកទាំង៤នេះ មានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការថែរក្សាឱវាទរបស់ព្រះអង្គ ត្រូវមានធម៌សាមគ្គីនិងចិត្តគំនិតរឹងប៉ឹង ជឿទុកចិត្តគ្នាទៅវិញទៅមក ជាពិសេសត្រូវចេះឱ្យតម្លៃគ្នាក្នុងការកសាងវត្តអារាម។ ប្រសិនបើបុគ្គលណាម្នាក់ក្នុងចំណោមអ្នកទាំង៤នោះ បានប្រព្រឹត្តខុសនូវប្រការណាមួយមិនសមរម្យ យើងត្រូវមានទស្សនៈទូលំទូលាយនឹងពិចារណារកហេតុផលឱ្យបានច្បាស់លាស់ ថានេះជារឿងរបស់បុគ្គលធ្វើខុសមិនមែនសង្គមធ្វើខុសទេ អ្នកធ្វើខុសត្រូវហ៊ានទទួលយកការពិតដើម្បីការពារផលប្រយោជន៍រួម ជាពិសេសពុទ្ធបរិស័ទត្រូវថ្លឹងថ្លែងពីព្រឹត្តិការណ៍ទាំងអស់នោះ ឱ្យមានតម្លាភាព និងយុត្តិធម៌ចំពោះអ្នកទទួលអនុវត្តការងារ ***(តទៅទំព័រទី២១)***

*(តមកពីទំព័រទី១)* ដែលបានរត់គេចពីការចាប់ខ្លួននៅកម្ពុជាក្រោមឱ្យជ្រកកោននៅកម្ពុជារហូត។ ក្រោយមក លោក **ទីម សាខន** ត្រូវបានក្រុមមន្ត្រីសង្ឃ និងរដ្ឋាភិបាលខ្មែរចាប់ផ្សឹក ហើយបញ្ជូនមកដាក់គុកយួននៅកម្ពុជាក្រោម ដោយចោទពីបទធ្វើឲ្យបែកបាក់មិត្តភាពវៀតណាមនិងកម្ពុជា។

ក្រោយពីបញ្ចប់សង្គ្រាមនេះ រដ្ឋាភិបាលយួនបានយកក្បាលខ្មែរក្រោម ដែលស្លាប់នៅស្រុកស្វាយទងនោះ[១]ធ្វើជាសារមន្ទីរតាំងពិពណ៌មួយ ក្នុងគោលបំណងឲ្យមតិជាតិ និង អន្តរជាតិបានជ្រាបនូវអ្វីមួយ



*លោកគ្រូ ទីម សាខន មុនមន្ត្រីសង្ឃខ្មែរចាប់ផ្សឹក*

ដែលរដ្ឋាភិបាលវៀតណាមចាត់ទុកថា នោះជាក្បាលរបស់ជនជាតិយួនដែលត្រូវកងទ័ពខ្មែរក្រហមសម្លាប់។

***ប្រវត្តិ៖***

លោក **ទីម សាខន**(ឈ្មោះផ្សេងៈ ទីម ខន , ចៅ ខននិងណុម សុខឃឿន) កើត ឆ្នាំ១៩៦៨ នៅភូមិអណ្តូងទរ(An Bình)ឃុំពោធិ (Ba Trúc) ស្រុកស្វាយទងខេត្តមាត់ជ្រូក ។

**ការជម្លៀសពីខេត្តមាត់ជ្រូកទៅខេត្តតាកែវ៖**

ឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហម នៃរបបកម្ពុជាប្រជាធិបតេយ្យបានវាយលុកចូលស្រុកស្វាយទង ខេត្តមាត់ជ្រូក ក្នុងគោលបំណងអ្វីមួយ ដែលគេចាត់ទុកថា ជាការរំដោះទឹកដីកម្ពុជាក្រោម ។

**-ការត្រឡប់ទៅសាងផ្នួសនៅខេត្តមាត់ជ្រូក៖**

ឆ្នាំ១៩៩០ បានត្រឡប់មក បួសនៅវត្តភ្នំពីរ ស្រុកស្វាយទងខេត្តមាត់ជ្រូករហូត ដល់ចុងឆ្នាំ១៩៩០ បានត្រឡប់ទៅគង់នៅវត្តភ្នំដិនខាងជើង ស្រុកគិរីវង់ ខេត្តតាកែវ ប្រទេសកម្ពុជាវិញ ។

**-ការឡើងធ្វើជាព្រះចៅអធិការវត្តនៅវត្តភ្នំដិនខាងជើង**

ឆ្នាំ១៩៩៣ ក្រោយពីបានមកគង់នៅវត្តភ្នំដិនខាងជើងអស់រយៈពេល៣ឆ្នាំមក លោក **ទីម សាខន** ត្រូវបានពុទ្ធបរិស័ទចំណុះជើងវត្ត និង លោកសង្ឃខ្មែរ **ទេព វង្ស** តែងតាំងជាព្រះចៅអធិការវត្តភ្នំដិនខាងជើង ស្រុកគិរីវង់ ខេត្តតាកែវ រហូតដល់ថ្ងៃចាប់ផ្សឹក។

**-ការចាប់ផ្សឹកដោយចោទពីបទធ្វើឲ្យបែកបាក់មិត្តភាព**



*ពីឆ្វេងទាំងស្តាំ៖ ទេព វង្ស, ឡុង គីម លាង និងសៅរ៍ ច័ន្ទ ថុល្ល*

**វៀតណាមកម្ពុជា៖**

ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៧ ត្រូវបាន គណៈសង្ឃនៃប្រទេសកម្ពុជាដឹកនាំដោយ **ទេព វង្ស, ឡុង គីម លាង, ណយ ច្រឹក, អម លឹម ហេង និងសៅច័ន្ទថុល្ល** សហការជាមួយ **ជៀស ឱម** ព្រះចៅអធិការវត្តសីហរតនារាមនិងជាមេគណ ខេត្តតាកែវ ចាប់ផ្សឹក ហើយចាប់បញ្ជូនមកដាក់គុកយួន នៅខេត្តមាត់ជ្រូក ដោយបានចោទពីបទថា បានធ្វើឲ្យបែកបាក់មិត្តភាពកម្ពុជាវៀតណាម។

មុនពេលចាប់ផ្សឹកនោះ សម្តេចសង្ឃ នន្ទ ង៉ែត សង្ឃនាយក នៃប្រទេសកម្ពុជា បានចេញលិខិតមួយច្បាប់ចុះថ្ងៃទី ១៦ ខែមិថុនាឆ្នាំ...... ***(តទៅទំព័រទី១០)***

# ដើម្បីផលប្រយោជន៍ជាតិត្រូវតែហ៊ានលះបង់

ដើម្បីសំរេចកិច្ចការអ្វីមួយ ដែលមានគុណប្រយោជន៍សម្រាប់ព្រះពុទ្ធសាសនានិងសង្គមជាតិ យើងទាំងអស់គ្នា ត្រូវហ៊ានតស៊ូពុះពារគ្រប់មធ្យោបាយក្នុងការស្វែងរកផ្លូវដែលល្អឆ្ពោះទៅកាន់សុខសន្តិភាព និងវឌ្ឍនភាពសង្គម។ ការងារទាំងនោះមិនធំជាងចិត្តយើងឡើយ ឱ្យតែយើងមានសេចក្តីក្លាហានគ្រប់គ្រាន់ហើយភារកិច្ចទាំងនោះនឹងសំរេចបានជោគជ័យយ៉ាងពិតប្រាកដ។

សេចក្តីលំបាកតែងមានជាមុនចំពោះការងារទាំងពួង ចំណែកសេចក្តីសំរេច រមែងសម្រេចមកជាខាងក្រោយ។ ក្នុងនោះផងដែរ ភាពនៃការលំបាក ច្រើនតែធ្វើឱ្យយើងមានទឹកចិត្តចុះខ្សោយគ្រប់ពេលវេលា វាជាហេតុញ៉ាំងអារម្មណ៍ របស់បុគ្គលគ្រប់រូបស្ថិតនៅក្រោមភាពតក់ស្លុតស្ទក់ មិនអាចស្ទុះទៅមុខបាន ធ្វើឱ្យចិត្តរួញរាមិនធ្វើអ្វីឡើយ។តែបើយើងមានទឹកចិត្តមនសិការជាតិ ហើយយល់ហេតុផលច្បាស់លាស់ ការងារធ្ងន់ៗទាំងនោះយើងនឹងធ្វើទៅបានដោយស្រួល ទោះជាត្រូវជួបបញ្ហាស្មុគ្រស្មាញយ៉ាងណាក្តីក៏នៅតែអាចយកជ័យជំនះបានមិនមានហេតុភេទអ្វីមករារាំង សូម្បីបន្តិចបន្តួចនោះឡើយ។

តាមការពិត ទោះបីការងារនោះ មានទំហំធំប៉ុនណាក៏ដោយ ក៏មិនមែនផុតវិស័យនៃមនុស្សយើងមិនអាចធ្វើបាននោះដែរ។អ្វីដែលថាលំបាកគឺចិត្តរបស់យើងវិញទេ ប្រសិនបើមនុស្សយើងគ្រប់រូបចេះអប់រំចិត្តបានល្អ នឹងបំបែកឧបស័គ្គប្រកបដោយជោគជ័យ។

ដើម្បីកសាងសង្គមមួយបាន ថ្នាក់ដឹកនាំគ្រប់អង្គការ សមាគមឬស្ថាប័ននីមួយៗ ត្រូវហ៊ានលះបង់ កំលាំងកាយ ចិត្ត កំលាំងប្រាជ្ញា ទ្រព្យធន និងពេលវេលាជាដើម។ កាលបើការងារយើងបានសំរេចហើយ រឿងមិនល្អទាំងប៉ុន្មាន ដែលនឹងកើតឡើងចំពោះយើងរាល់គ្នា សំខាន់ជាងនេះទៅទៀត វាអាស្រ័យទៅលើការបកស្រាយយ៉ាងល្អត្រឹមត្រូវជាក់ស្តែង តាមរយៈការលេចចេញជារូបរាង នៃលទ្ធផលការងារ។

សេចក្តីក្លាហាននិងការតស៊ូព្យាយាម ប្រកបទៅដោយទឹកចិត្តមនសិការជាតិនោះមានភាពសំខាន់ខ្លាំងណាស់ ចំពោះមនុស្សគ្រប់រូប។ ចំណែកចិត្តដែលពោរពេញទៅដោយស្មារតីរឹងប៉ឹង គឺរឹងរឹតតែត្រូវការណាស់ទៀត ពីព្រោះនេះជាសញ្ញាមួយសម្រាប់ដាស់តឿនភាពក្លាហាន វាបានបញ្ចេញថាមពលរបស់ខ្លួនឱ្យបានពេញលេញគ្រប់គ្រាន់ ប្រកបដោយតម្លាភាព និងសមត្ថភាពជាពិសេសរឿងដែលពាក់ព័ន្ធនឹងជីវិតផ្ទាល់ យើងត្រូវចេះបែងចែកពេលវេលា និង រៀបចំផ្លូវឱ្យច្បាស់លាស់សំរាប់ដើរទៅរកការអភិវឌ្ឍន៍សង្គមជាតិ។ជីវិតគឺជាការតស៊ូ មានជីវិតត្រូវមានសង្ឃឹមមិនត្រូវអស់សង្ឃឹមមុនពេលជីវិតរស់នៅឡើយ នឹងត្រូវចេះបណ្តុះបណ្តាលកំលាំងសាមគ្គីព្រមទាំងសំដែងភាពស្មោះត្រង់នឹងគ្នាទៅវិញទៅមក ស្របតាមឪវាទព្រះពុទ្ធសំដែងថា សាមគ្គីនាំមកនូវសេចក្តីចំរើន រុងរឿង ថ្កុំថ្កើង និងផ្តល់មកនូវប្រយោជន៍នាពេលបច្ចុប្បន្ន និងទៅអនាគត។

សង្គមណាមួយបើខ្វះការសាមគ្គី សង្គមនោះមិនរីកចំរើនបានឡើយ គឺទទួលនូវភាពបរាជ័យជាក់ជាមិនខាន។ មនុស្សយើងម្នាក់ៗត្រូវចេះកែប្រែខ្សែជីវិតនិងអប់រំចិត្តខ្លួនឯងឱ្យរួចផុតពីអវិជ្ជាទៅកាន់ជីវិតល្អ លោតចេញពីជីវិតល្អ ឆ្ពោះទៅកាន់ជីវិតប្រសើរ រត់ចេញពីជីវិតប្រសើរ តម្រង់ទៅកាន់ជីវិតឧត្តម គឺស្ទុះទៅមុខជាលំដាប់លំដោយគឺមិនមានទីបំផុតនៃការកំណត់ទេ ដោយយើងត្រូវប្រើប្រាស់ ឱ្យអស់ពីសមត្ថភាពនៃសេចក្តីក្លាហាន។នេះហើយគឺជាការសំរេចជោគវាសនាសំរាប់ខ្លួនឯង និងសង្គមជាតិ។

ដើម្បីភាពជោគជ័យ សំរាប់ការងារនីមួយ អ្វីដែលយើងត្រូវធ្វើគឺត្រូវធ្វើជាដាច់ខាត និងភាពអង់អាចហើយត្រូវជំរុះចោលនូវការរារែកដែលការសង្ស័យផ្សេងៗបំរុងកើតឡើងឬកើតហើយក្តី៕ ***ដោយ កូនខ្មែរ***

# លោក សម រង្ស៊ី ជួបសំណេះសំណាលជាមួយសមាជិក-កា នៅវត្តខេមរង្សី ក្រុងសាន់ហូសេ្ស

កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១០កន្លងទៅហើយនេះ សាខាគណៈបក្សសម រង្ស៊ី នៅទីក្រុងសាន់ហូសេ្ស រដ្ឋកាលីហ្វ័រញ៉ា បានរៀបចំពិធីទទួលស្វាគមន៍ លោក**សម រង្ស៊ី** ប្រធានគណៈបក្សសម រង្ស៊ី និង លោក **ស៊ាន ប៉េងសែ** ប្រធានគណៈកម្មការព្រំដែនខ្មែរនៅប្រទេសបារាំង អញ្ជើញមកសួរសុខទុក្ខនិងជួបសំណេះសំណាលជាមួយសមាជិក សមាជិកា នៅវត្ត**ខេមរង្សី** ក្រោមការជួយសំរួល និងផ្តល់ទីកន្លែងពីសំណាក់ព្រះសង្ឃ គណៈកម្មការ អាចារ្យវត្ត**ខេមរង្សី** ក្រុងសាន់ហូសេ្សផង។

នៅក្នុងពិធីជួបជុំនោះដែរ ដោយមានសមាជិក-កា អញ្ជើញមកពីទីក្រុងផ្សេងៗនិងបណ្តារដ្ឋនានាជាង ១៣០នាក់មកចូលរួមស្តាប់និងពិភាក្សាអំពីព្រឹត្តិការណ៍នយោបាយនៅប្រទេសកម្ពុជា ដែលបានកើតឡើងនាពេលបច្ចុប្បន្ននិងទៅអនាគត។ ជាពិសេសទាក់ទងនឹងបញ្ហាព្រំដែន និងជនអន្តោប្រវេសន៍យួនដែលកំពុងរស់នៅយ៉ាងរំភើយនៅលើទឹកដីនៃប្រទេសកម្ពុជា។



*ព្រះសង្ឃស្វាធ្យាយជយន្តោ ជូនលោកសម រង្ស៊ី និងលោក ស៊ាន ប៉េងសែ ក្នុងពិធីជួបសំណេះសំណាលជាមួយសមាជិក-កា*

បន្ទាប់ពីការឧទ្ទេសនាម និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំសាខាគណៈបក្សសម រង្ស៊ី ប្រចាំនៅទីក្រុងសាន់ហូសេ្សរួចមក លោកប្រធានសម រង្ស៊ីបានធ្វើសេចក្តីថ្លែងការណ៍ ស្តីពីព្រឹត្តិការណ៍យ៉ាងក្តៅគគុក គឺបញ្ហាបង្គោលព្រំដែន រវាងប្រទេសកម្ពុជា និងប្រទេសវៀតណាមនៅខេត្តស្វាយរៀង កាលពីពេលថ្មីៗនេះ។




*លោក សម រង្ស៊ី ប្រធានគណៈបក្ស សម រង្ស៊ី*

រដ្ឋាភិបាលកម្ពុជាបានចោទប្រកាន់លោកថា បង្អស្តេរភាពនយោបាយ គឺការដកបង្គោលតំរុយព្រំដែនដែលរដ្ឋអំណាចយួនបានបោះនៅលើដីខ្មែរនៅខេត្តស្វាយរៀង ដោយសារបញ្ហានេះ តុលាការខេត្តស្វាយរៀងបានធ្វើតាមបញ្ជាពីស្រុកយួន កាត់ទោសឲ្យលោកជាប់គុកចំនួន២ឆ្នាំ រហូតដល់១៨ឆ្នាំទៀតផង។ លោកបានបញ្ជាក់ថាអ្វីដែលលោកធ្វើគឺដើម្បីការពារផលប្រយោជន៍ជាតិ ជាពិសេសប្រជាពលរដ្ឋខ្មែរក្រីក្រត្រូវបានអ្នកមានអំណាចជិះជាន់ប្លន់យកដីស្រែ ផ្ទះសម្បែង ហើយចាប់ដាក់គុកទាំងអយុត្តិធម៌ធ្វើឲ្យខ្មែររងទុក្ខវេទនា ក្រោមស្នាដៃរដ្ឋអំណាចអាយ៉ងយួន។ អ្នកដែលកាត់ទឹកដីខ្មែរឲ្យបរទេស អ្នកនោះហើយជាមនុស្សក្បត់ជាតិ តែឥឡូវនេះគណៈបក្សសម រង្ស៊ី មានឧបករណ៍ទំនើបសំរាប់វាស់វែងទឹកដីកុំឲ្យបាត់បង់។ លោកប្រធានមានប្រសាសន៍បន្ថែមទៀតថា លោកនិងសមាជិក -កា គណៈបក្សទាំងអស់នឹងនៅតែតស៊ូការពារស្វែងរកការពិតជូនជនរួមជាតិគ្រប់កាលៈទេសៈមិនតែប៉ុណោះលោកបានលើកពីគុណសម្បត្តិរបស់បងប្អូនខ្មែរក្រោម ដែលបានរួមចំណែកបំរើផលប្រយោជន៍ជាតិជាមួយលោក ក្នុងការអភិវឌ្ឍន៍ប្រទេស។

លោកបានលើកពីការធ្វើសម្បទានសេដ្ឋកិច្ច ដីធ្លីរបស់រដ្ឋាភិបាលបច្ចុប្បន្នទៅឲ្យក្រុមហ៊ុនបរទេសគ្រប់គ្រងរាប់រយឆ្នាំ ចំណុចនេះហើយធ្វើខ្មែរបាត់បង់ដីធ្លី និងការងារ។ការដឹកនាំរបៀបនេះ...(តទៅទំព័រទី១៤)



អតីតសង្ឃ ទឹម សាខន ក្នុងសវនាការយួន ក្នុងខែត្រ

*(តមកពីទំព័រទី៧)* ២០០៧ ជាភាសាយួននិងខ្មែរស្នើទៅសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្សសម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចាប់ព្រះតេព្រះគុណ **ទឹម សាខន** ព្រះចៅអធិការវត្តភ្នំដិនខាងជើងផ្សឹក។ ក្នុងលិខិតនោះដែរ សង្ឃនាយកនន្ទ ង៉ែត បានចោទព្រះតេជព្រះគុណ **ទឹម សាខន** ថា *បានប្រព្រឹត្តខុសនិងវិន័យព្រះពុទ្ធសាសនា ដែលធ្វើឲ្យបែកបាក់សាមគ្គីជាតិ-អន្តរជាតិ ជាពិសេសរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម យកទីអាវាសវត្តធ្វើជាទីបញ្ជាការ សម្រាប់បម្រើចលនាឃោសនាដែលធ្វើឲ្យប៉ះពាល់ដល់វិន័យ និងសេចក្តីថ្លៃថ្នូរព្រះពុទ្ធសាសនា*[២] ។ ក្រោយពីបានពិនិត្យលិខិតនេះ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក៏បានយល់ព្រម ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៧ ។

បន្ទាប់ពីបានបោះត្រាពីសម្តេចសង្ឃខ្មែរទាំងពីរអង្គនេះរួចមករដ្ឋាភិបាលវៀតណាមបានយកលិខិតនេះទៅប្រកាសជាសាធារណៈដល់ពលរដ្ឋខ្មែរក្រោមនៅខេត្តមាត់ជ្រូកឲ្យបានជ្រាបជាមុន ដើម្បីជាការគំរាមដល់ស្មារតីពលរដ្ឋខ្មែរក្រោម និងព្រះតេជព្រះគុណ **ទឹម សាខន** មុនពេលគេអនុវត្តផែនការចាប់ផ្សឹកនោះ។

**បាត់ខ្លួន៣ខែ ៨ថ្ងៃលេចមុខនៅក្នុងវង់ក្រចកសេះយួន៖**

ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៧ តុលាការប្រជាជនយួនបានកាត់ទោសឲ្យលោក **ទឹម សាខន** ជាប់គុករយៈពេល១២ខែ ចោទពីបទថា ធ្វើឲ្យបែកបាក់មិត្តភាពយួន-ខ្មែរ ក្រោយពីការចាប់ផ្សឹកលោកនៅវត្តសីហរតនារាមទីក្រុងតាកែវ ដោយអាជ្ញាធរនិងក្រុមមន្ត្រីសង្ឃខ្មែររួចបញ្ជូន មកដាក់គុកយួនបាត់ដំណឹងមិនដឹងថាស្លាប់ឬរស់អស់ ៣ ខែ ៨ ថ្ងៃមក។ **(តទៅទំព័រទី១៦)**

## ដំណឹងសិក្សា
## ភាសាខ្មែរ និងរបាំប្រពៃណីបុរាណខ្មែរ

*ពុទ្ធិកសមាគមខ្មែរក្រោម* ***វត្តខេមររង្សី*** *និងក្រុមរបាំអប្សរា នៅទីក្រុងសាន់ហូសេ្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់បងប្អូនជនរួមជាតិខ្មែរ គ្រប់មជ្ឈដ្ឋាន ឲ្យបានជ្រាប សូមទានជ្រាប ៖*

*** *កម្មវិធីសិក្សាភាសាខ្មែរ ជារៀងរាល់ថ្ងៃសុក្រ និងសៅរ៍ ចាប់ពីម៉ោង* **4:00PM - 5:00PM**

*** *កម្មវិធីបង្ហាត់របាំប្រពៃណីខ្មែរ ជារៀងរាល់ថ្ងៃសុក្រ ចាប់ពីម៉ោង* **6:00PM - 8:00PM**

*អាស្រ័យហេតុនេះ សូមអញ្ជើញអាណាព្យាបាល និងសិស្សានុសិស្ស គ្រប់ស្រទាប់វណ្ណៈ ដែលមានទឹកចិត្តស្រឡាញ់ និងលើកស្ទួយវិស័យវប្បធម៌ខ្មែរ មេត្តារួសរាន់នាំបុត្តធីតារបស់លោក អ្នក មកសិក្សាភាសាខ្មែរ និងរបាំប្រពៃណីជាតិ ដោយសោមនស្សរីករាយ។*

*** ***ទីកន្លែង:*** *វត្តខេមររង្សី* **1594 Cunningham Ave, San Jose. CA 95122 Tel: (408) 923-2166**

# ព្រះមហាប្រសិទ្ធិវ៉ារៈកាន់ លោកគ្រូចៅអធិការវត្តរតនគិរីវង្ស នាទីក្រុង San Bernardino ទទួលអនិច្ចធម្ម

កម្មជាផៅពង្ស កម្មជាមត៌កមិនមានបុគ្គលណាមួយគេចឱ្យផុតពីសេចក្តីស្លាប់បានឡើយ សង្ខារធម៌នៃសព្វសត្វទាំងអស់មិនទៀងទាត់ទេកើតឡើងហើយនឹងវិនាសទៅវិញជារឿងធម្មតា មុននិងក្រោយទៅតាមកម្មល្អ កម្មអាក្រក់ដែលមនុស្សម្នាក់ៗបានកសាងទុកមក។

កាលពីថ្ងៃទី៣០ខែឧសភាឆ្នាំ២០១០កន្លងទៅថ្មីៗនេះ គណៈកម្មការ អាចារ្យវត្ត ព្រមទាំងពុទ្ធបរិស័ទ **វត្តរតនគិរីវង្ស**នាទីក្រុង San Bernardino រដ្ឋកាលីហ្វ័រញ៉ា មានទុក្ខក្រៀមក្រំជាទីបំផុត ដោយព្រះ**មហាប្រសិទ្ធិវ៉ារៈកាន់** ដែលជាលោកគ្រូចៅអធិការវត្ត ព្រះអង្គបានទទួលអនិច្ចធម្ម កាលពីវេលាម៉ោង ៣និង២០នាទីរសៀល នៅក្នុងមន្ទីរពេទ្យ Medical Center of San Bernardino ដោយរោគាពាធក្នុងព្រះជន្មាយុ ៦២វស្សា។



*ព្រះសង្ឃវត្តខេមរវង្សីនិមន្តទៅចូលរួមធ្វើពិធីជាបង្សុកូល ប្រគេនចំពោះព្រះវិញ្ញាណក្ខន្ធព្រះ**មហាប្រសិទ្ធិវ៉ារៈកាន់**ចៅអធិកា **វត្តរតនគិរីវង្ស** នៅទីក្រុង San Bernardino*

លោកគ្រូ **មហាប្រសិទ្ធិវ៉ារៈកាន់** ព្រះអង្គជាខ្មែរសុរិន្ទ មានស្រុកកំណើតនៅ ឃុំថៃប៉ឹង ស្រុកថៃប៉ឹង ខេត្តស៊ីសាកែតប្រទេសថៃ។ ព្រះអង្គប្រសូតិនៅថ្ងៃទី១៤មិថុនាឆ្នាំ១៩៤៨ឪពុកឈ្មោះ កាន់ យុវង្ស ម្តាយឈ្មោះភឿង ម៉ា ព្រះតេជគុណមានបងប្អូនទាំងអស់៦នាក់ ស្រី២ ប្រុស៤។

ព្រះមហាប្រសិទ្ធិ បានលះបង់ភាពជាគ្រហស្ថ ចូលសាងផ្នួសតាំងពីអាយុ១៤ឆ្នាំមកម្ល៉េះ។ កាលនៅថៃលោកមានតួនាទីជាអនុគណខេត្តសុរិន្ទទៀតផង។



*ព្រះមហាប្រសិទ្ធិវ៉ារៈកាន់ ព្រះចៅអធិការវត្តរតនគិរីវង្ស*

ព្រះពុទ្ធសាសនា ជាសាសនាមួយដឹកនាំមនុស្សមិនឱ្យប្រកាន់វណ្ណៈ ពូជសាសន៍អ្វីទេ ហេតុនេះទើបគណៈកម្មការ អាចារ្យនិងពុទ្ធបរិស័ទបាននិមន្តលោកគង់នៅក្នុង **វត្តរតនគិរីវង្ស** ដើម្បីជាស្រែបុណ្យសំរាប់ពុទ្ធបរិស័ទធ្វើទានបំពេញកុសល រហូតដល់ថ្ងៃព្រះអង្គទទួលអនិច្ចធម្ម។



*ពុទ្ធបរិស័ទចូលរួមពិធីបុណ្យបង្សុកូលព្រះមហាប្រសិទ្ធិវ៉ារៈកាន់*

យោងតាមប្រសាសន៍ លោកព្រឹទ្ធាចារ្យ **លឹម ខាយ** អាចារ្យវត្ត**វត្តរតនគិរីវង្ស** បាន*(តទៅទំព័រទី១៥)*

# ការមិនសេពគប់បុគ្គលពាល

នៅលើពិភពលោកយើងនេះ មានមនុស្សច្រើនប្រភេទណាស់ តែបើនិយាយដោយសង្ខេបមានពីរប្រភេទគឺ មនុស្សល្អនិងមនុស្សអាក្រក់ ល្អឬមិនល្អ យើងអាចសង្កេតដឹងបានតាមរយៈទង្វើឬ អត្តចរិត នៃបុគ្គលម្នាក់ៗ។ បុគ្គលទាំងនោះ អាចធ្វើឱ្យអ្នកចូលទៅសេពគប់ជាមួយក្លាយជាមនុស្សល្អឬមនុស្សអាក្រក់តាមរយៈខ្លួនទៀតផង។

ព្រះសម្មាសម្ពុទ្ធបានណែនាំសព្វសត្វទាំងអស់ឱ្យសិក្សាពីលក្ខណៈបុគ្គលមិនល្អជាមុន ដើម្បីវៀរចាកឱ្យឆ្ងាយពីបុគ្គលនោះ ព្រោះថាមនុស្សពាលអាចដឹកនាំយើងរាល់គ្នាប្រព្រឹត្តនូវអំពើអាក្រក់ឬអបាយមុខ ដូចជាការលេងល្បែងពាលា ស្រីស្រា សេពគ្រឿងញៀននឹងនាំឱ្យប៉ះពាល់ដល់ស្ថេរភាពសង្គមជាតិ និងប្រយោជន៍ផ្ទាល់ខ្លួនផងដែរ។

យោងតាមការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញបានបញ្ជាក់ថា សិរីសួស្តីដំបូងនៃជីវិត គឺមិនសេពគប់បុគ្គលពាល។ ពាក្យថាបុគ្គលពាល មានន័យថា មានជីវិតត្រឹមតែដកដង្ហើមចេញចូល មិនបានធ្វើអ្វីជាប្រយោជន៍សំរាប់ខ្លួនឯង និងសង្គមជាតិ និងមានចេតនាក្នុងការបំផ្លិចបំផ្លាញផលប្រយោជន៍បច្ចុប្បន្ន និង បរលោក បុគ្គលបែបនេះគ្មានសមត្ថភាពគ្រប់គ្រងខ្លួនឯងទេតែងបណ្តោយទៅតាមខ្សែជីវិត រស់នៅដោយគ្មានគោលដៅច្បាស់លាស់ ធ្វើអ្វីៗតាមតែចិត្តនឹកឃើញ មិនបានពិចារណារកហេតុផលទេ ព្រមទាំងចូលចិត្តបំផ្លាញកិត្តិយសរបស់ខ្លួន និងអ្នកដទៃ។

បុគ្គលពាលតែងប្រព្រឹត្តនូវអំពើដូចខាងក្រោមនេះគឺៈ

### ក/ការប្រព្រឹត្តដោយកាយ៣យ៉ាង

១- ការកាប់សម្លាប់ និងបៀតបៀនជីវិតអ្នកដទៃ។

២- ដើរឆបោក លួចប្លន់ កេងប្រវ័ញ្ចទ្រព្យសម្បត្តិគេជាដើម។

៣- ការប្រព្រឹត្តអនាចារ ទៅលើកូនប្រពន្ធគេ។

បុគ្គលពាលប្រព្រឹត្តធ្វើអំពើទាំងអស់នេះ យ៉ាងសប្បាយរីករាយ ដោយគ្មានការគិតពីវិនាសអន្តរាយអ្វីចំពោះសេចក្តីទុក្ខដល់អ្នកដទៃឡើយ។ ប្រសិនជាអ្នកណាម្នាក់បានទៅសេពគប់ជាមួយបុគ្គលនោះ មិនយូរប៉ុន្មាននឹងក្លាយទៅជាបុគ្គលនោះដែរ។

### ខ/ការប្រព្រឹត្តអាក្រក់ដោយវាចាមាន៤យ៉ាងគឺៈ

១- និយាយភូតភរ កុហក ឆបោកអ្នកដទៃ។

២- និយាយពាក្យគំរោះគំរើយ ជេរប្រទេច ផ្តាសាគេឯង។

៣- និយាយពាក្យស៊ិកសៀត ញុះញង់ ចាក់ដោតបំបែកបំបាក់អ្នកដទៃ។

៤- និយាយពាក្យឥតប្រយោជន៍ ឥតខ្លឹមសារគ្រាន់តែរលាស់ដូចអណ្តាតអត់ឆ្អឹង។

បើយើងកើតមកបានរស់នៅជាមួយម្តាយឪពុកដែលចេះពោលពាក្យអាក្រក់ កូនក៏ពោលពាក្យអាក្រក់ដែរ បើនិយាយពាក្យផ្អែមល្ហែម យើងក៏និយាយពាក្យផ្អែមល្ហែមដែរ យ៉ាងណាមិញ បើយើងទម្លាប់និយាយពាក្យអាក្រក់ អាសអាភាស តាមមិត្តអាក្រក់នោះ យើងនឹងក្លាយទៅជាមនុស្សគ្មានសីលធម៌និងគ្មានជីវធម៌មិនខានឡើយ។

### មនុស្សមានគំនិតអាក្រក់៣យ៉ាងគឺៈ

ក-ល្មោភ លោភលន់ចង់បានទ្រព្យសម្បត្តិអ្នកដទៃមកធ្វើជារបស់ខ្លួន។

ខ- ចងអាឃាត ព្យាបាទ គំនុំគំកួនជាមួយអ្នក ភូមិផងរបងជាមួយ។

គ- ដោយការយល់ខុសថា គ្មានបាប គ្មានបុណ្យគ្មានគុណគ្មានទោសជាដើម។

សរុបសេចក្តីមក តែងតែប្រព្រឹត្តនូវអំពើអកុសលកម្មបថទាំង១០ប្រការជានិច្ចគ្រប់.. *(តទៅទំព័រទី២១)*

# ឧបករណ៍ភ្លេងខ្មែរ



*ខ្សែដៀវឬសាយដៀវឧបករណ៍ភ្លេងរបស់ខ្មែរយើង*

តាមទម្លាប់គេតែងតែនាំគ្នាហៅឧបករណ៍ នេះថា ខ្សែដៀវ ឬសាដៀវ ឬសាយដៀវ។ សាយមានន័យថា សំណុំសរសៃសូត្រតូច ដែលចងពីក្បាលស្លាបឯកភ្ជាប់នឹងចុងដង( សាយឯក, ឯកដាច់សាយ ) ។ ដៀវមានន័យថា មួយ ឬតែ១ គេនិយាយថា ទឹមដៀវ គឺទឹមសត្វតែ១, រាំដៀវ គឺរាំម្នាក់ម្តង, ភ្លេងដៀវ គឺភ្លេងលេងម្នាក់ម្តង,ខ្សែដៀវគឺខ្សែ១។ ឧបករណ៍ខ្សែដៀវនេះកាលពីសម័យដើមដ៏យូរលង់មកហើយ មានខ្សែសំនៀងធ្វើអំពីសំណុំសរសៃសូត្រវេញចូលគ្នា។ សម័យបច្ចុប្បន្ននេះគេយកខ្សែលោហធាតុមកប្រើជំនួសវិញ។ ឧបករណ៍នេះជាដំបូងប្រើប្រាស់នៅក្នុងវង់ភ្លេងអារក្ស ក្រោយមកទើបគេឃើញមានប្រើនៅក្នុងវង់ភ្លេងការបុរាណ។ ប៉ុន្តែនៅដើមសតវត្សទី២០នេះគេឃើញមានអ្នកចំរៀងទោលខ្លះយកឧបករណ៍នេះ មកកេះកំដរចំរៀងរបស់ខ្លួនដូចជា លោកតាភីរម្យ ង៉ុយ កវីដ៏កំពូលច្រៀងផងកេះខ្សែដៀវផង ពីកន្លែងមួយទៅកន្លែងមួយរហូតដល់ទទួលមរណភាព ( ១៨៦៥-១៩៣៦ )។

តាមការសន្និដ្ឋានរបស់ដូនតាយើងតៗ គ្នាមកឱ្យដឹងថា ខ្សែដៀវមានអាយុរាប់ពាន់ឆ្នាំមកហើយក្នុងសង្គមកម្ពុជាយើងដោយឧបករណ៍នេះ មានឆ្លាក់រូបភាពជាប់នឹងក្បាច់ផ្តែររចនាបថសំបូរព្រៃគុកនៅសតវត្សទី៧ ឆ្លាក់នៅនឹងជញ្ជាំងប្រាសាទបាយ័នប្រាសាទអង្គរវត្តដែលបានកសាងឡើងតាំងពីសតវត្សទី៩រហូតដល់ សតវត្សទី១៣។ រូបចម្លាក់ទាំងនោះបញ្ជាក់ថា ឧបករណ៍ខ្សែដៀវនេះមានមុនសតវត្សទី៧ទៅទៀត ហើយមានប្រយោជន៍សំខាន់ណាស់ក្នុងសង្គម ទើបដូនតាយើងសម័យនោះយកមកឆ្លាក់ជាប់នឹងជញ្ជាំងប្រាសាទបែបនេះ។ រូបភាពនៅលើជញ្ជាំងប្រាសាទបែបណាបច្ចុប្បន្ននេះខ្សែដៀវនៅតែមានរូបរាងយ៉ាងនោះដដែល ។ ខ្សែដៀវនៅកម្ពុជាយើងបច្ចុប្បន្ននេះមាន៖

-ដងធ្វើអំពីប្រភេទឈើរឹង ដូចជាឈើ នាងនួន ឈើគ្រញូង និង ឈើខ្មៅមានរាងមូល រាវងផ្នែកខាងចុង។ នៅខាងចុងដងគេ ច្រើនតែឆ្លាក់ក្បាលពស់ នាគរាជជាលំអ។ ដងចែកជាពីរកំណាត់ដែលអាចដកចេញដាក់ចូលភ្ជាប់គ្នាបានក្នុងពេលត្រូវការ។

-ព្រលួតមានតែមួយធ្វើអំពីឈើរឹងក្រឡឹងយ៉ាងស្អាតសំរាប់រឹតខ្សែសំនៀង ហើយស្ថិតនៅផ្នែកខាងគល់នៃដង ។

-ស្នូកធ្វើអំពីសំបកឃ្លោកក្អម កាត់យកពាក់កណ្តាលទុកខាងផ្នែកស្លួចចងភ្ជាប់ទៅនឹងគល់ដង សំរាប់ធ្វើជាប្រអប់សំនៀង។ នៅពេលសំដែងម្តងៗគេយកស្នូកមកផ្អឹបនឹងទ្រូង ដើម្បីឱ្យមានសំនៀងខ្ទរ ឬគេអង្រន់ស្នូកដើម្បីឱ្យមានសំនៀងញ័រ។

-ខ្សែសំនៀងមាន១ ធ្វើអំពីសរសៃលោហធាតុខ្សែសំនៀងនេះចងលាតសន្ធឹងពីចុងដងទៅព្រលួត ដោយមានខ្សែកចងផ្គោបជាប់ទៅនឹងដងត្រង់ជិត ប្រអប់សំនៀង។

-ក្រចកកេះ ធ្វើអំពីបន្ទះលោហធាតុមូរល្មមស៊កនាងដៃបាន ហើយកាត់បញ្ឆិតចុងទុកល្មមអាចកេះខ្សែបានស្រួល។

-នៅពេលកេះខ្សែម្តងៗ គេត្រូវយកគល់ចង្អុលដៃទៅប៉ះនឹងខ្សែ ហើយដកចេញយ៉ាងរហ័សដើម្បីឱ្យសំនៀងលាន់ឮឡើងតូមៗ ដែលជាលក្ខណៈសំនៀងរបស់ខ្សែដៀវ បើមិនធ្វើយ៉ាងនេះទេ សំនៀងនឹងឮស្អូរទឹងៗ ដូចខ្សែល្អួសហាលខោអាវវិញ ។

នៅពេលប្រគំម្តងៗ ខ្សែដៀវ*( តទៅទំព័រទី១៦ )*

# ដំណឹងមរណភាព



**SAROYA RAMA HAO**

ខ្ញុំបាទ **ហាវ ម៉ុនសេខ** ព្រមទាំងបុត្រធីតា មានទុក្ខក្រៀមក្រំ ដោយអ្នកស្រី **Saroya Rama Hao** ដែលត្រូវជាភរិយា ជាម្តាយ និងជាជីដូន បានទទួលមរណភាព កាលពីថ្ងៃអាទិត្យទី៣០ ខែឧសភា ឆ្នាំ២០១០ វេលាម៉ោង១០ និង៤០នាទីយប់។ ក្នុងជន្មាយុ៥៨ឆ្នាំ ដោយរោគាពាធ នៅមន្ទីរពេទ្យ**Kaiser** ទីក្រុង **Sacramento** រដ្ឋកាលីហ្វ័រញ៉ា។

ដំណឹងនេះ ចាត់ទុកជាសេចក្តីអញ្ជើញបងប្អូនញាតិមិត្តជិតឆ្ងាយ ដើម្បីចូលរួមបុណ្យបូជាសព ដែលមានកម្មវិធីដូចខាងក្រោម ៖

| | |
|---|---|
| ***Agenda*:**<br>**Friday 6/4/2010: 4PM to 7PM**<br>***Open casket Viewing:***<br>***Saturday 6/5/2010: 2PM to 5PM***<br>***និមន្តព្រះសង្ឃទទួលកត្ត នៅគេហដ្ឋាននៃសព*** | ***Address***<br>**Mount Vernon Memorial Park & Mortuary**<br>8201 Greenback Lane.<br>Fair Oaks, CA 95628<br>Contact Phone Numbers: (916) 798-2466 |

*(តមកពីទំព័រទី៩)* មិនខុសអីពីរបបខ្មែរក្រហមទេ គឺគេសម្លាប់យើងតាមបែបនយោបាយត្រជាក់។



*ប្រជាពលរដ្ឋខ្មែរ ចូលរួមស្តាប់សេចក្តីថ្លែការណ៍ របស់លោក សម រង្ស៊ី នៅវត្តខេមររង្សី នាទីក្រុងសាន់ហូសេ្ស*

បន្ទាប់ពីលោកប្រធានសម រង្ស៊ី មានប្រសាសន៍រួចមក លោក ស៊ាន ប៉ែងសែ ប្រធានគណៈកម្មការព្រំដែនខ្មែរ បញ្ជាក់ពីផែនទីព្រំដែនខ្មែរជូនអង្គប្រជុំឱ្យបានជ្រាបថាតើទឹកដីខ្មែរមានការបាត់បង់យ៉ាងណាខ្លះគឺខ្មែរមានការបាត់បង់ទឹកដីយ៉ាងច្រើន ទាំងព្រំដែនគោក ព្រំដែនទឹក និងកោះមួយចំនួនត្រូវប្រទេសជិតខាងរំលោភយក។

លោកសម រង្ស៊ីបានបញ្ជាក់បន្ថែមថា រដ្ឋអំណាចយួនបានបោះបង្គោលព្រំដែនចូលដីខ្មែរពី៣០០ទៅ៧០០ម៉ែត្រនៅគ្រប់ខេត្តដែលជាប់នឹងប្រទេសយួន ដូច្នេះយើងត្រូវរកវិធីការពារសូម្បីមួយចំអាមក៏មិនឱ្យបាត់ដែរ។ ទាក់ទិននឹងការបោះឆ្នោតវិញ គឺយើងទាំងអស់គ្នាខិតខំប្រឹងប្រែងធ្វើបែបណា កុំឱ្យពួកផ្តាច់ការប្លន់ស្លឹកឆ្នោតបងប្អូនបាន ជាពិសេសពួកយួនខុសច្បាប់ មករស់នៅប្រទេសកម្ពុជាកាន់តែច្រើនឡើងហើយរដ្ឋអំណាចកំពុងតែការពារ។ បើនិយាយពីជនអន្តោប្រវេសន៍យួនវិញ មានតែបងប្អូនខ្មែរក្រោមទេ ទើបយល់ច្បាស់ថានរណាជាយួននោះ រីឯការអប់រំយើងត្រូវពង្រឹងឱ្យបានល្អប្រសើរនៅពេលខាងមុខ គឺត្រូវរៀនសូត្រ រៀនគិត ដើម្បីអនាគតវែងឆ្ងាយលប់បំបាត់អំពើពុករលួយ បក្សពួកនិយមជាដើម។

លោកប្រធានបានលើកបញ្ហាព្រះតេជគុណ ទឹម សាខន ដែលរដ្ឋាភិបាលខ្មែរចាប់បញ្ជូនឱ្យរដ្ឋអំណាចយួនដាក់គុក និងសូមអំពាវដល់បងប្អូនខ្មែរលើ ខ្មែរក្រោម ខ្មែរកណ្តាល រួបរួមគ្នា សាមគ្គីគ្នា កសាងប្រទេសជាតិឱ្យបានរីកចំរើន និងឈរលើគោលការណ៍ស្នេហាជាតិខ្ពស់ ដើម្បីការពារសិទ្ធិសេរីភាពប្រជាពលរដ្ឋខ្មែរកំពុងរងទុក្ខនៅលើទឹកដីរបស់ខ្លួនឱ្យរួចផុតពីកៀបសង្កត់ និងឱ្យទទួលបាននូវលទ្ធិប្រជាធិបតេយ្យដូចពលរដ្ឋនៅលើពិភពលោកដែរ៕

*(តមកពីទំព័រទី១១)* បញ្ជាក់អ្នកយកពត៌មានយើងថា ព្រះគ្រូ**មហាប្រសិទ្ធិវ៉ារៈភាន់** គង់នៅក្នុង **វត្តរតនគិរីវង្ស** ធ្វើជាព្រះគ្រូចៅអធិការវត្តអស់ចំនួន១៧វស្សា។ លោកបានយកព្រះទ័យទុកដាក់ក្នុងការថែរក្សាទំនៀមទម្លាប់ប្រពៃណីព្រះពុទ្ធសាសនា ធ្វើឱ្យពុទ្ធបរិស័ទទូទៅកោតសរសើរមិនដាច់ពីមាត់ ស្របពេលនេះដែរ លោកអាចារ្យ **លឹម ខាយ** សូមអំពាវនាវចំពោះព្រះតេជគុណគ្រប់អង្គ និងពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន មេត្តាជួយឧបត្ថម្ភគាំទ្រក្នុងពិធីបុណ្យបូជាព្រះសពនេះ ឱ្យបានច្រើនកុះករ ដើម្បីឧទ្ទិសមហាកុសលប្រគេនដល់ព្រះវិញ្ញាណក្ខ័ន្ធលោកគ្រូចៅអធិការវត្ត។

*សូមបញ្ជាក់ថា ពិធីបូជាព្រះសពនឹងប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោមនេះ៖*

<u>ថ្ងៃសុក្រ ទី១១ ខែមិថុនា ឆ្នាំ២០១០ (Friday, June 11, 2010)</u> ចាប់ពីម៉ោង 6:00 PM ជួបជុំពុទ្ធបរិស័ទ នមស្សការ,សមាទានសីល, និមន្តព្រះសង្ឃចំរើនព្រះបរិត្ត ក្នុង**វត្តរតនគិរីវង្ស**។

<u>ថ្ងៃសៅរ៍ ទី១២ ខែមិថុនា ឆ្នាំ២០១០ (Saturday,June12, 2010)</u> ចាប់ពីម៉ោង 9:00 AM នមស្សការ,សមាទានសីល,រាប់បាត្រ,វេរភត្តប្រគេនព្រះសង្ឃ និងជាវបង្សុកូល ឧទ្ទិសកុសលព្រះគេនវិញ្ញាណក្ខ័ន្ធសព **ព្រះមហាប្រសិទ្ធិវ៉ារៈភាន់** នៅ**វត្តរតនគិរីវង្ស**។

ម៉ោង 12:30 PM-2:00 PM ពិធីបូជាព្រះសពតាមប្រពៃណីព្រះពុទ្ធសាសនា។

**ទីកន្លែង៖** 570 E. Highland Ave. **San Bernardino, CA 92404**

<u>ថ្ងៃអាទិត្យ ទី១៣ ខែមិថុនា ឆ្នាំ ២០១០ (Sunday, June13, 2010)</u> ចាប់ពីម៉ោង 9:00 AM នមស្សការ,សមាទានសីល,រាប់បាត្រ,វេរភត្តប្រគេនព្រះសង្ឃជាវបង្សុកូល និមន្តព្រះសង្ឃសំដែងធម៌ទេសនាជាកិច្ចបង្ហើយបុណ្យ នៅ**វត្តរតនគិរីវង្ស**។

*ពត៌មានបន្ថែមសូមទំនាក់ទំនងលេខទូរស័ព្ទ* **(951) 324-3927 (909) 242-3567 (909) 887-0737 .**

ដំណឹងនេះ ចាត់ទុកជាសេចក្តីនិមន្តនិងអញ្ជើញព្រះតេជគុណ ព្រមទាំងពុទ្ធបិស័ទជិតឆ្ងាយ ដើម្បីចូលរួមបុណ្យបូជាព្រះសពនិងបុណ្យទក្ខិណានុប្បទាននេះផងដែរ៕

---




6492 Ferne Ave. Cypress, CA 90630 Tel: (714) 425-0652

## *សេចក្តីអញ្ជើញ*

យើងខ្ញុំមានកិត្តិយស សូមគោពអញ្ជើញមិត្តរួមអាវុធទាំងអស់គ្រប់ជាន់ថ្នាក់ អស់លោក លោកស្រី មិត្តភក្តិ អ្នកនាងកញ្ញា មកចូលរួមកំសាន្តដោយមេត្រីភាព សមភាព និង ភាតរភាព ក្នុង៖

## ពិធីជួបជុំអតីតយុទ្ធជនទ័ពអាកាសខ្មែរឆ្នាំ២០១០

(KHMER AIR FORCE VETERANS REUNION 2010)

ដែលប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ទី១០ខែកក្កដាឆ្នាំ២០១០

វេលាម៉ោង ៥និង៣០នាទីល្ងាចនៅ

**ភោជនីយដ្ឋានព្រះច័ន្ទពេញវង់**

**1458 Atlantic Ave.**
**Long Beach, CA 90813**
**Tel: (562) 599-5457**
**(Reservation required)**

*ពត៌មានបន្ថែមសូមទំនាក់ទំនងលោក៖* Luong Sar

(714) 425-0652

*lousar@sonic.net or visit www.khmerairforce.com*

*(តមកពីទំព័រទី៤)* ដាក់សម្ពាធបន្ថែមនិងជាការគំរាមមកលើធន្ទះ ស្មារតីប្រជារាស្ត្រខ្មែរក្រោមម្ចាស់ទឹកដី ដើម្បីខ្មែរក្រោមបំភ្លេចនូវរាល់ក្តីឈឺចាប់និងរាល់ទុក្ខលំបាកទាំងឡាយ ដែលជាជម្ងឺរ៉ាំរ៉ៃមួយជិតជាមជាប់នៅក្នុងជីវភាពរបស់ប្រជារាស្ត្រខ្មែរក្រោម។ទង្វើទាំងនេះ មិនអាចធ្វើឲ្យខ្មែរក្រោមស្គាល់នូវសិទ្ធិសេរីភាព ស្គាល់ភាពរុងរឿង និងទទួលបាននូវមោទនភាព ក្នុងនាមជាជាតិសាសន៍មួយមានអធិបតេយ្យភាពនិងភាពជាម្ចាស់ការក្នុងការសម្រេចវាសនារបស់ខ្លួនឡើយ។ផ្ទុយទៅវិញ នេះគ្រាន់តែជាការបំភាន់ភ្នែកសាធារណជនថា អាជ្ញាធរយួនមានការចាប់អារម្មណ៍ចំពោះខ្មែរក្រោមតែប៉ុណ្ណោះ ហើយលទ្ធផលជាវិជ្ជមានត្រូវបានមកបក្សកុម្មុយនិស្ត និង រដ្ឋាភិបាលយួនតែម៉្យាង។

សូមអំពាវនាវដល់បងប្អូនខ្មែរក្រោម ទាំងអស់កុំព្រងើយកន្តើយឡើយ ត្រូវតែប្រើប្រាស់សិទ្ធិ របស់បងប្អូនហ៊ាននិយាយហ៊ានស្តីទៅកាន់ពួកមេដឹកនាំយួនទាំងនោះនូវរាល់ទុក្ខកង្វល់របស់បងប្អូន។ ទាមទារឲ្យមេដឹកនាំបក្សនិងរដ្ឋាភិបាលយួនទាំងនោះ ប្រគល់មកវិញនូវសិទ្ធិទ្រព្យសម្បត្តិទាំងឡាយ មានដីធ្លីជាដើមនិងប្រគល់មកវិញនូវសិទ្ធិសេរីភាព គោរពជំនឿសាសនា សិទ្ធិរក្សាវប្បធម៌ ប្រពៃណី អក្សរសាស្ត្រជាតិរបស់យើង សិទ្ធិរស់នៅ សិទ្ធិមានសន្តិសុខផ្ទាល់ខ្លួន មានការដកហូតឲ្យអស់នូវកម្លាំង តាមដានគម្រាមកំហែងបំភិតបំភ័យស្មារតីបងប្អូនជាដើម ៕

*(តមកពីទំព័រទី១៣)* មិនដើរផ្លូវរាបសាដូចឧបករណ៍ដទៃឡើយ គឺដើរផ្លូវផ្តក់មុខផ្តក់ក្រោយ ធ្វើឱ្យសំនៀងរបស់ខ្លួនលេចធ្លោឡើងនៅក្នុងចំណោមឧបករណ៍ដទៃ ។

តាមប្រសាសន៍ដូនតាយើងបានឱ្យដឹងថា រូបរាងខ្សែដៀវទាំងមូលតំណាងឱ្យសត្វពស់ នាគរាជ ជាសត្វតំណាងភាពត្រជាក់ត្រជុំ មានសច្ចធម៌ មានសុភមង្គលក្នុងជីវិត ៕

*(ស្រាវជ្រាវចងក្រងដោយ លោក ហ៊ិន សារិន សាស្ត្រាចារ្យសិល្បៈតន្ត្រី)*

*(តមកពីទំព័រទី១០)* ក្រោយពីជាប់គុកអស់រយៈពេលជាង ១ឆ្នាំ និងជាប់គុកក្នុងផ្ទះអស់១ឆ្នាំ អាជ្ញាធរយួនក៏បាន ផ្តល់ឱកាសដល់លោកបានត្រឡប់ទៅស្រុក ដើម្បីជួបជុំគ្រួសារនៅភូមិភ្នំដិន ខេត្តតាកែវ។ ពេលបានទៅដល់ភូមិកំណើត អាជ្ញាធរកម្ពុជាមិនព្រមធ្វើអត្តសញ្ញាណប័ណ្ណជូនលោកដែលបាត់នូវសិទ្ធិជាប្រជាពលរដ្ឋខ្មែរឡើយ។


*លោក ទឹម សាខន ផ្តល់បទសម្ភាសន៍ដល់វិទ្យុអាស៊ីសេរី បន្ទាប់ពីចេញពីគុកយួន*

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ អាជ្ញាធរយួនខេត្តមាត់ជ្រូកបានចេញអត្តសញ្ញាណប័ណ្ណ សញ្ជាតិវៀតណាមដល់លោក **ទឹម សាខន** ដោយដាក់ឈ្មោះតាមអក្សរយួនថា Tim Sà Khonl កើតឆ្នាំ១៩៦៨ នៅភូមិ An Bình ឃុំ Ba Chúc ស្រុក ស្វាយទង (Tri Tôn) ខេត្តមាត់ជ្រូក សាសនាព្រះពុទ្ធ(Tôn Giáo Đạo Phật) ជនជាតិខ្មែរ (Khơme) ។

ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០០៨ បានចេញពីគុកយួន តែជាប់គុកនៅផ្ទះវិញ។

ថ្ងៃទី ៣១ ខែមីនា ២០០៩ អាជ្ញាធរយួន បានផ្តល់លិខិតបើកផ្លូវព្រំដែនវៀត ណាម-កម្ពុជា ដល់លោក **ទឹម សាខន** ។

*(តទៅទំព័រទី២០)*

# ជីវប្រវត្តិសង្ខេប និង ការតស៊ូរបស់វីរសមណៈ ហែម ចៀវ (តពីលេខមុន)

ដូច្នេះហើយ បានជាអ្នកស្រុកស្រែចំការហាម មិនអោយកូនធ្វើទាហានទេ ព្រោះខ្លាចគេស្អប់ រហូតដល់សព្វថ្ងៃ។ ក្រុមទាហានទាំងនោះ ចូលទៅដល់ភូមិណា ភូមិនោះមុខជាហិនហោចទ្រព្យសម្បត្តិមិនខាន ។ នេះជានយោបាយបំបែកបំបាក់ដើម្បីត្រួតត្រារបស់ចោរព្រៃបារាំង។ គ.ស១៩៤០ កងទ័ពជប៉ុនក៏ចូលមកដល់ *(សូមមើលគុកនយោបាយរបស់លោក ប៊ុណ្ណ ចន្ទម៉ុល បើចង់ជ្រាបច្បាស់)* ដើម្បីវាយកំចាត់សត្រូវរបស់ខ្លួន គឺ បារាំង អាមេរិកាំង អង់គ្លេសនៅក្នុងឥណ្ឌូចិនទាំងមូល ពេលនោះ កងទ័ពបារាំង មានកំលាំងខ្សោយណាស់ទៅហើយ ។ ខ្មែរយើងឃើញដូច្នេះ ក៏ចូលទៅទាក់ទងនឹងជប៉ុន ដើម្បីអោយគេជួយ ពួកជប៉ុនក៏យល់ព្រមតាមសេចក្ដីស្នើរបស់លោក **សឺង ង៉ុកថាញ់** ដែលជាអ្នកតំណាងក្រុមបដិវត្តន៍។ នៅពេលទេសនាម្ដងៗ ព្រះអាចារ្យ**ហែម ចៀវ**បានលើកយកពុទ្ធភាសិតសំខាន់ៗ ដែលទាក់ទងនឹងជីវភាពប្រជារាស្ត្រ ដើម្បីអោយជ្រាបច្បាស់បានដឹងច្បាស់នូវគោលបំណង នៃព្រះបរមគ្រូរបស់យើង។ ពុទ្ធភាសិតទាំងនោះគឺ

- កុំធ្វើមនុស្សអោយចង្អៀតលោក ។
- ត្រូវគិតបច្ចុប្បន្នអោយបានសុខជាមុន ព្រោះថាបើបានសុខក្នុងបច្ចុប្បន្នហើយ អនាគតមុខជាបានសុខទៀត ។
- ត្រូវខំធ្វើការ កុំដេកផ្សងសំណាង ។
- កន្លងសេចក្ដីទុក្ខបាន ព្រោះព្យាយាមខ្ជាប់ខ្ជួន ។
- មានតែខ្លួនយើងទេ ដែលជាទីពំនឹងបាន ។
- បុគ្គលមិនគប្បីសេពគប់នូវមិត្តដ៏លាមកទាំងឡាយឡើយមិនគប្បីសេពគប់នូវបុរសដ៏ទាបថោកទាំងឡាយឡើយ គប្បីសេពគប់តែនឹងកល្យាណមិត្តទាំងឡាយគប្បីសេពគប់នូវបុរសដ៏ឧត្តមទាំងឡាយ(១០០គាថា) មនុស្សឥតប្រាជ្ញារមែងណែនាំនូវចំណែក ដែលមិនគួរណែនាំ រមែងដឹកនាំអោយប្រកបក្នុងចំណែកដែលមិនជាធុរៈ ជាមនុស្សគឺគេណែនាំ ឬ ប្រដៅអោយបានល្អដោយលំបាក កាលបើគេនិយាយល្អៗ ក៏ស្រាប់តែប្រលោតខឹង មនុស្សនោះ មិនចេះដឹងវិន័យច្បាប់អ្វីឡើយ កិរិយាមិនជួបប្រទះ ឬ មិនឃើញនូវមនុស្សដូចនោះជាការល្អ (១០០គាថា) បុគ្គលមិនគួរអាស្រ័យអ្នកដទៃចិញ្ចឹមជីវិតឡើយ។



ប្រាសាទអង្គរវត្ត, វិមានឯករាជ្យ, និងវីរសមណៈ ហែម ចៀវ

ពុទ្ធភាសិតទាំងអស់នេះ លោកចង់អោយប្រជារាស្ត្រមានសេរីភាព ដោយពឹងផ្អែកលើខ្លួនឯងជាមូលដ្ឋានកុំផ្ញើវាសនាទៅលើស្ដេច ដែលជាមនុស្សឃោរឃៅសប្បាយភ្លេចជាតិនោះមិនល្អទេ។ ក្រៅពីលើកពុទ្ធភាសិតលោកអាចារ្យបានទាញឧទាហរណ៍ល្អៗពីប្រទេសនានា ដែលគេចេះកសាងជាតិអោយបានរុងរឿងគ្រប់វិស័យ។មិនត្រឹមតែបណ្ដុះស្មារតីអោយខ្មែរក្រោកឈរប្រយុទ្ធយកឯករាជ្យពីបារាំងនោះទេ លោកបានបណ្ដុះស្មារតីកូនខ្មែរអោយស្រលាញ់ការសិក្សា អោយយល់តំលៃនៃវិជ្ជាថែមទៀតផង។ មហាវិស្សមកាលក៏ចូលមកដល់... ព្រះអាចារ្យ **ហែម ចៀវ** បាននិមន្តទៅវត្តកំណើតដើម្បីសួរសុខទុក្ខញោមញាតិនិងភិក្ខុសាមណេរឯទៀតដែលរាប់អានគ្នា ។ នៅពេលយប់ឡើង មានចាស់ៗស្រីប្រុស និង ភិក្ខុសាមណេរបានមកចោមរោម ដើម្បីអោយលោកអធិប្បាយធម៌ ឬ រឿងរ៉ាវផ្សេងៗអោយស្ដាប់ ។

មុនដំបូងលោកលើករឿង... ***(តទៅទំព័រទី១៩)***

# អាជ្ញាធរនៅមណ្ឌលគិរីបង្កការលំបាកដល់ពលរដ្ឋក្នុងការខ្ចីប្រាក់ពីធនាគារ

ប្រជាពលរដ្ឋនៅស្រុកកែវសីមាខេត្តមណ្ឌលគិរី មានទុក្ខកង្វល់ជាខ្លាំង ខណៈភាពរាំងស្ងួតបណ្ដាលឲ្យដំណាំពួកគាត់ខូចខាតអស់ម្ដងហើយម្ដងទៀត ត្រូវការខ្ចីប្រាក់ពីធនាគារទិញពូជដាំដុះហើយជួបឧបសគ្គ ដោយ អាជ្ញាធរភូមិឃុំមិនចុះហត្ថលេខាបញ្ជាក់លើពាក្យសុំខ្ចីប្រាក់នោះ។តំណាងសហគមន៍ភូមិអូរស្នែង ឃុំស្រែខ្ទុម ស្រុកកែវសីមា ខេត្តមណ្ឌលគិរី បានថ្លែងប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី១៧ខែឧសភា ថា នៅចំពោះមុខនេះ មានប្រជាពលរដ្ឋកំពុងត្រូវការប្រាក់កម្ចីពីធនាគារ ប៉ុន្តែភាគច្រើនបំផុតនៃពលរដ្ឋទាំងនេះមិនត្រូវបានអាជ្ញាធរភូមិឃុំចុះហត្ថលេខាលើលិខិតខ្ចីប្រាក់ពីធនាគារឲ្យឡើយ។តំណាងសហគមន៍ភូមិអូរស្នែងលោកហួស សាលី បានរៀបរាប់ថា អ្នកភូមិទាំងឡាយណាដែលព្រមផ្តិតមេដៃឲ្យអាជ្ញាធរលើការវាស់បញ្ជាក់ក្បាលដីជាមុនសិន ទើបអាជ្ញាធរព្រមចុះហត្ថលេខា លើលិខិតសុំខ្ចីប្រាក់ពីធនាគារបាន។ លោក ហួស សាលី បានបញ្ជាក់ថា ៖ *«ក្រុមហ៊ុន រិទ្ធីគិរីសីមា គេធ្វើគម្រោងដើម្បីបើអូសយកដីធ្លីនេះទៅធ្វើជាដីសម្បទាន។ ដល់អ៊ីចឹងប្រជាពលរដ្ឋភ័យខ្លាចមិនចូលរួមធ្វើការវាស់វែងដីនេះបានទេ!អ៊ីចឹងការមិនចូលរួម អាជ្ញាធរឃុំស្រុកបានដាក់គំនាបយ៉ាងធ្ងន់ធ្ងរ ដោយមិនចុះហត្ថលេខាលើលិខិតប្រជាពលរដ្ឋត្រូវខ្ចីលុយអេស៊ីលីដា(ធនាគារ)»*។មីតវ៉ាន់សូត្រអាយុ ៤៣ឆ្នាំ ជាកសិកររស់នៅភូមិអូរស្នែង បានឲ្យដឹងថា លោកត្រូវការខ្ចីប្រាក់ពីធនាគារចំនួន ៣០០០ ដុល្លារ ដើម្បីយកមកទិញពូជដី ដាំដំឡូង និងថែទាំកៅស៊ូ លើផ្ទៃដីចម្ការទំហំ១៧ហិកតារ ប៉ុន្តែភូមិឃុំមិនចុះហត្ថលេខាលើលិខិតខ្ចីប្រាក់។ ករណីអាជ្ញាធរមិនចុះហត្ថលេខាឲ្យដោយសារតែលោកមិនព្រមឲ្យអាជ្ញាធរទាំងនោះ វាស់ជំរឿនក្បាលដីលំនៅឋានរបស់លោក។ កសិករម្នាក់ទៀតឈ្មោះ មាស ខេន រស់នៅភូមិអូរស្នែង ឃុំស្រែខ្ទុម ជាមួយគ្នាបានបញ្ជាក់ថា នៅពេលលោកកាន់លិខិតសុំខ្ចីប្រាក់ទៅឲ្យមេឃុំបញ្ជាក់នោះ ពួកអាជ្ញាធរគេតម្រូវឲ្យលោកផ្តិតមេដៃលើការជំរឿនដីជាមុនសិនដែរ ហើយលោកក៏បានផ្តិតមេដៃឲ្យទៅដើម្បីបានការបញ្ជាក់ពីភូមិឃុំខ្ចីប្រាក់ពីធនាគារយកមកទិញពូជដំឡូងមី។ ការផ្តិតមេដៃនោះ ធ្វើឲ្យលោកបារម្ភខ្លាចបាត់បង់ដីចម្ការដូចគ្នាដែរ ប៉ុន្តែលោកគ្មានជម្រើសផ្សេង។ លោក មាស ខេន បានឲ្យដឹងថា ៖ *«ខ្ញុំទៅស៊ីញ៉េ ឃុំៗអត់ស៊ីញ៉េឲ្យ ទាល់តែខ្ញុំផ្តិតមេដៃរឿងវាស់ដីហើយ បានគេស៊ីញ៉េ គេវ៉ៃត្រាឲ្យ!»*។ ចាស់ទុំភូមិអូរស្នែង លោក សុខ យ៉ែម បានរិះគន់ថា អាជ្ញាធរបានប្រើវិធីនេះដើម្បីគាបសង្កត់ឲ្យអ្នកភូមិផ្តិតមេដៃឲ្យលើការជំរឿនក្បាលដី ហើយអ្នកភូមិព្រួយបារម្ភពីការបាត់បង់ដីចម្ការ នៅពេលដែលព្រមផ្តិតមេដៃឲ្យគេនោះ។




*ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅប្រទេសកម្ពុជា*

លោកបានរៀបរាប់បែបនេះថា៖ *«ធ្លាក់ភ្លៀងទៅនាំគ្នាដាំឡើងអស់ដីលើងអស់ទាំងពូជ ស្រាប់តែរាំងដល់ ២០ថ្ងៃ ងាប់អស់រលីង! ទិញពូជដាំមួយសាទៀត អាហ្នឹងនៅមានលុយបន្ត។ ដល់លើកទី៤ អស់រលីង ហើយឥឡូវត្រូវតែខ្ចីធនាគារដើម្បីជាពូជ។ ឯមេឃុំហ្នឹងមិនចុះហត្ថលេខា!»*។ មេឃុំស្រែខ្ទុមមិនអាចទាក់ទងបានទេ កាលពីព្រឹកថ្ងៃទី១៧ ខែឧសភា។ ដោយឡែកមេភូមិអូរស្នែង លោក ខៀវ សំបូរ បញ្ជាក់ថា ដរាបណាប្រជាពលរដ្ឋមិនបានឲ្យវាស់វែង និង មិនបានផ្តិតមេដៃលើការស្រង់ទំហំដីលំនៅឋាន........**(តទៅទំព័រទី២២)**

***(តមកពីទំព័រទី១៧)*** អ្វីផ្សេងៗ ដែលមានប្រយោជន៍ ទើបលោកមានថេរដីកាមួយៗ *«ប្រទេសយើងមិនដឹងពេលណារួចពីខ្ញុំបារាំងទេ។ បារាំងមកត្រួតត្រាស្រុកយើងហិនហោចទ្រព្យសម្បត្តិអស់ គ្មានអ្វីចំរើនរុងរឿងសោះ ដូចយើងរាល់គ្នាឃើញស្រាប់ហើយ អាត្មាធ្វើបុណ្យរាល់ថ្ងៃបួងសួងសុំអោយខ្មែរបានឯករាជ្យមកវិញ ដើម្បីកុំអោយបរទេសជិះជាន់យើងតទៅទៀត »។*

**ពេលនោះលោកតាម្នាក់ពោលឡើង**

• ករុណាម្ចាស់ ក៏គិតដូចលោកគ្រូអាចារ្យដែរ តែមិនដឹងធ្វើម៉េចបានឈ្នះពួកបារាំងទេ ។ ចំណុចនេះ បានធ្វើអោយទឹកព្រះទ័យព្រះអាចារ្យរីករាយពេកក្រៃ លោកក៏តបដោយសំលេងក្រអួនព្រមទាំងញញឹមផង។

• ពរជាការងាយទេ លោកតា បើយើងចង់បានឯករាជ្យ ព្រោះព្រះសម្មាសម្ពុទ្ធទ្រង់បង្ហាញផ្លូវអោយយើងដើរហើយថា *«សេចក្តីសាមគ្គីនាំមកនូវសេចក្តីសុខគ្រប់យ៉ាង»* ។ តែកាលណាយើងស្រុះស្រួលគ្នា យើងនឹងអាចធ្វើអ្វីៗកើតមិនខាន។ អាត្មាសង្ឃឹមថា បើប្រជារាស្ត្រយើងស្រុះស្រួលគ្នា មុខជាឈ្នះបារាំងពេលឆាប់ៗនេះមិនខាន។ តែបើខ្មែរយើងមិនស្របគ្នាទេ យើងពុំអាចដណ្តើមយកសេរីភាពនោះមកវិញបានឡើយ។

អាត្មាមិនពេញចិត្តនឹងអ្នកខ្លះ ដែលគេយកព្រះពុទ្ធសាសនា ដើម្បីបំភ័ន្តមតិប្រជារាស្ត្រ ហើយបោកប្រជារាស្ត្រជាដាច់ខាត។ លោក តា! លោកទាំងអស់ឃើញស្រាប់ហើយ ប្រទេសយើងមានអ្នកបន្លំខ្លួនកេងយកកំរៃពីសាសនាសំបើមណាស់។

ករុណាម្ចាស់ពិតហើយការនេះ!ការសន្ទនាអំពីរឿងសាសនា នយោបាយ និងអំពីការណែនាំអោយប្រជាជនចេះប្រកបការងារចិញ្ចឹមជីវិត ស្របតាមគន្លងព្រះសម្ពុទ្ធបានប្រព្រឹត្តទៅ រហូតពាក់កន្តាលអាធ្រាត្រទើបឈប់។ពេលនិមន្តទៅស្រុកម្តងៗ ព្រះអាចារ្យតែងនិមន្តគ្រប់ផ្ទះបងប្អូនណាដែលក្រីក្រជាងគេ។ លោកពេញចិត្តប្រាស្រ័យជាមួយជនជំពូកនោះ ដូចជាលោកពេញចិត្តនឹងភូមិកំនើតឬព្រះសម្ពុទ្ធដែរ។

**ព្រះបាឡាត់ ហែមចៀវ ត្រូវបារាំងចាប់ផ្សឹក**

ព្រះអាទិត្យជិតអស្តង្គតរលត់រស្មីទៅហើយ សំលេងរៃយំគ្រលួច ពីលើចុងគគីមកប៉ះត្រចៀកបុព្វការីជនអោយស្រងេះស្រងោចខ្លោចផ្សា ស្មើទប់ជលនេត្រពុំបាន។ឆ្នាំ១៩៤២ជាឆ្នាំដែលប្រទេសយើងត្រូវបាត់បង់អ្នកស្នេហាជាតិមាតុភូមិអស់ជាច្រើន។ ព្រឹត្តិការណ៍សកលលោក បានតឹងតែងជាលំដាប់។ សង្គ្រាមលោកលើកទី២ក៏ផ្ទុះឡើង។ស្ថានការណ៍ក្នុងប្រទេសខ្មែរមានសភាពតឹងតែងស្ទើរតែកែលែងរួច ព្រោះប្រជាជនខ្មែរយើងហាក់ដូចជាលង់លក់ ដោយមិនដឹងថា ប្រទេសអញនៅក្រោមអំណាចរបស់បារាំងទេ។ តែបើដឹងវិញក៏គ្រាន់តែត្រឹមដឹងស្ទើរមិនហ៊ានធ្វើសកម្មភាពអ្វីឡើយ។តើដោយសារអ្វី? ជនជាតិខ្មែរដែលបារាំងចាប់ខ្លួនគ្មានវរជនឬ ស្តេចណាទៅសូមតវ៉ាអោយរួចខ្លួនមកវិញទេ។ គេបែរជាជំរុញអោយបរទេសសំលាប់ចោលទៅវិញ។ ម៉្លោះហើយ អ្នកមានចំណេះតិចរមែងខ្លាចស្លាប់ជាធម្មតា ការភ័យខ្លាចក៏កើតមានឡើង។តែខ្មែរឈាមអង្គរវត្ត ធ្លាប់ធ្វើជាមហាអំណាចមួយនឹងគេដែរ ក៏ក្រោកឈរទាញដៃបងប្អូនឈាមខ្លួនអោយតស៊ូប្រយុទ្ធឡើង។ ក្រុមបដិវត្តន៍បានតស៊ូធ្វើសកម្មភាពរបស់ខ្លួនយ៉ាងមមាញឹក ដើម្បីអោយទាន់ស្ថានការណ៍ សកលលោកដែលកំពុងច្បាំងគ្នា។ ពេលនោះព្រះអាចារ្យហែមចៀវតែងនិមន្តទៅអប់រំខ្មែរស្រុកស្រែចំការជាញឹកញយ ដើម្បីសូមការឧបត្ថម្ភពីប្រជារាស្ត្រគ្រប់មធ្យោបាយ និងគ្រប់សំភារៈ។ចំណែកប្រជារាស្ត្រ និងព្រះសង្ឃ បានគាំទ្រក្រុមបដិវត្តន៍ ទាំងផ្លូវចិត្ត ផ្លូវកាយឥតសង្ស័យឡើយ។ ផែនការសំងាត់របស់ខ្មែរបដិវត្តន៍បានដឹងដល់ក្រសួងស៊ើបអង្កេតនៃពួកបរទេស ការនេះដឹងដោយសារទាហានខ្មែរ យើងដែលនៅស្រលាញ់បារាំង ហើយយកការណ៍ទៅអោយបារាំង ដើម្បីខ្លួនបានបុណ្យស័ក្តិ (១)។តាម *«សៀវភៅគុកនយោបាយ* ***(តទៅទំព័រទី២៩)***

*(តមកពីទំព័រទី១៦)* ថ្ងៃទី០៤ ខែមេសា ឆ្នាំ ២០០៩ ប្រកព្រំដែនកម្ពុជានៃខេត្តតាកែវ បានផ្តល់ទិដ្ឋាការដល់លោក **ទឹម សាខន**ចូលទៅទឹកដីកម្ពុជារយៈពេល១៥ថ្ងៃចាប់ពីថ្ងៃ ទី០៤ ដល់ ១៧ ខែមេសា ឆ្នាំ២០០៩ ដើម្បីធ្វើបុណ្យលើកសពញោមស្រីរបស់ខ្លួន ដែលបានស្លាប់កាលពីឆ្នាំ២០០១ ។

ថ្ងៃទី១៤ ខែមេសា ឆ្នាំ ២០០៩ លោក **ទឹម សាខន** បានភៀសខ្លួនទៅប្រទេសថៃ ដើម្បីសុំសិទ្ធិជ្រកកោនជាជនភៀសខ្លួនផ្នែកនយោបាយពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR) នៅទីក្រុងបឹងកក់ ក្រោយពីរដ្ឋាភិបាលខ្មែរមិនព្រមផ្តល់អត្តសញ្ញាបណ្ណសញ្ជាតិខ្មែរដល់រូបលោក។

**ការធ្វើដំណើរទៅប្រទេសទី៣ ៖**

ក្រោយពីបានទទួលឋានៈជាជនភៀសខ្លួនពីឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR)នៅទីក្រុងបឹងកក់ ប្រទេសថៃមក នៅថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០០៩ លោក **ទឹម សាខន** ត្រូវបាន UNHCR បញ្ជូនទៅរស់នៅស៊ុយអែត ជាប្រទេសទី៣ ដោយសុវត្ថិភាព។

**ការអញ្ជើញមកដល់សហរដ្ឋអាមេរិកៈ**

ដើម្បីលាតត្រដាងសេចក្តីពិត នៃការរំលោភសិទ្ធិមនុស្ស និងជំនឿសាសនានៅលើទឹកដីកម្ពុជាក្រោម ជូនមតិជាតិនិងអន្តរជាតិឱ្យបានជ្រាបច្បាស់ អតីតអ្នកបួសខ្មែរក្រោម៣រូបដែលបានរួចផុតពីការចាប់ដាក់គុក នៅប្រយួននោះ កាលពីថ្ងៃទី១៦ ខែមេសាឆ្នាំ២០១០កន្លងមកនេះ បានអញ្ជើញមកសហរដ្ឋអាមេរិក ចូលបង្ហាញខ្លួនជាសាក្សីរស់ នៅក្នុងកិច្ចប្រជុំនៃវេទិការអចិន្ត្រៃយ៍ ស្តីពីជនជាតិដើមនៅអង្គការសហប្រជាជាតិនាបុរីញ៉ូវយ៉ក កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០។



*លោកទឹម សាខន លោកគឹម មឿន លោក យ៉ញ តូន អញ្ជើញមកដល់សហរដ្ឋអាមេរិក*




*ព្រះតេជគុណ ទឹម សាខន ព្រះអង្គ គឹម មឿន ព្រះអង្គ យ៉ញ តូន និងថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក*

ដោយនៅមានសេចក្តីស្រឡាញ់ភេទជាបព្វជិតនៅឡើយ លោកទឹម សាខន បានសំរេចចិត្តសាងព្រះផ្នួសឡើងវិញ នាថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១០ នៅវត្តសុរិយាវង្សីទីក្រុង Philadelphia ក្រោមអធិបតីភាពព្រះតេជគុណ **ត្រឹង គីចន្ទា** ដោយមានការឧបត្ថម្ភគាំទ្រពីសហព័ន្ធខ្មែរកម្ពុជាក្រោម និងគណៈកម្មការវត្តសុរិយាវង្សី ព្រមទាំងពុទ្ធបិស័ទនៅគ្រប់មជ្ឈដ្ឋានទាំងអស់។

ការបួសឡើងវិញរបស់ព្រះតេជគុណ **ទឹម សាខន** គឺជាការលះបង់មួយសំខាន់ណាស់ សំរាប់ ជាតិ ព្រះពុទ្ធសាសនា និងមាតុភូមិខ្មែរយើង ដើម្បីការពារថែរក្សា វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ អក្សរសាស្ត្រជាតិឱ្យបានគង់វង្ស ព្រមទាំងការពារសិទ្ធិសេរីភាពជូនបងប្អូនខ្មែរក្រោម និងស្វែងរកផ្លូវឆ្ពោះទៅកាន់សិទ្ធិសំរេចវាសនាខ្លួន ដោយខ្លួនឯងជាដើម៕

(តមកពីទំព័រទី១២) ពេលវេលា។

មិត្តភក្តិអាក្រក់ នៅពេលដែលមានលុយកាក់ គេនាំយើងដើរស៊ីចាយសប្បាយហ៊ឺហា ដល់ពេលអស់លុយកាលណាបែកគំនិតនាំគ្នាដើរលួច ប្លន់ ទ្រព្យសម្បត្តិគេ តែបើសិនជាពួកគេខឹងនឹងអ្នកណាម្នាក់ហើយ ពិតជាពួកគេព្រួតដៃវាយសំពងអ្នកនោះ ដោយគ្មានការត្រាប្រណីឡើយ។

**គ/ការប្រព្រឹត្តរបស់បុគ្គលពាល**

ការត្រួតពិនិត្យអត្តចរិតរបស់មនុស្សពាលបានទៅតាមលក្ខណៈដូចខាងក្រោមនេះ៖

១/ ដើរក្នុងផ្លូវខុស អបាយមុខៗ លេងល្បែងស្រីស្រាផ្តេសផ្តាស់ ដែលជាហេតុនាំឱ្យកើតជម្ងឺផ្សេងៗ និងប្រព្រឹត្តពាលាអាវ៉ាសែ សេពគ្រឿងញៀន កត្តានេះហើយអាចធ្វើឱ្យប៉ះពាល់សង្គមគ្រួសារ និងសង្គមជាតិផងដែរ។

២/ ចូលចិត្តរំខាន ឆាឆៅ ឬជ្រៀតជ្រែកដល់ការរស់នៅនិងការសិក្សារបស់អ្នកដទៃ។

៣/ ចូលចិត្តប្រព្រឹត្តរឿងខុស ដឹងថាខុសវិន័យសាលា ឬខុសច្បាប់ចរាចរណ៍ឬរកស៊ីមុខរបរខុសច្បាប់ហើយនៅតែធ្វើ។

៤/ មិនព្រមអនុវត្តឬប្រតិបត្តិច្បាប់ទម្លាប់នៅក្នុងទីកន្លែងនីមួយៗ ហេតុនេះប្រសិនបើយើងសង្កេតឃើញលក្ខណៈមិនល្អបែបនេះហើយ យើងត្រូវតែព្យាយាម កុំនៅក្បែរ កុំដើរជាមួយ កុំយកធ្វើជាមិត្តភក្តិជិតស្និទ្ធឡើយព្រោះអាចធ្វើឱ្យយើងខូចខ្លួនតាមមិត្តភក្តិនោះដែរ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ការមិនសេពគប់បុគ្គលពាលជាមង្គលដ៏ឧត្តុង្គឧត្តម ព្រោះថាយើងបានលះបង់នូវផ្លូវអន្តរាយផ្សេងៗ ហើយឈានដើរក្នុងផ្លូវដ៏ត្រឹមត្រូវ ជាជំហានដំបូងដើម្បីកសាងអនាគតសំរាប់ខ្លួនផ្ទាល់ និងសង្គមជាតិផងដែរ៕

---

(តមកពីទំព័រទី៦)



ព្រះសង្ឃនិមន្តបិណ្ឌបាត្រ នៅពេលបុណ្យវិសាខបូជា នាវត្តខេមរង្សី

បន្ត ទោះបីនៅក្នុងអង្គការ សមាគមឬវត្តអារាមក្តី។ យោងតាមទ្រឹស្តីព្រះពុទ្ធសាសនា បានបញ្ជាក់យ៉ាងច្បាស់ថា ការកសាងអំពើល្អ អាក្រក់សំរាប់ខ្លួនឯងម្នាក់គាត់ មិនអាចអូសទាញអ្នកអត់កំហុសមកលាយឡំជាមួយបានទេហេតុនេះសូមពុទ្ធបរិស័ទត្រិះរិះពិចារណាធ្វើយ៉ាងណារួមចិត្តរួមគំនិតថែរក្សាសាសនាព្រះពុទ្ធឱ្យបានរុងរឿង ប្រកបដោយសទ្ធាជ្រះថ្លា។ម្យ៉ាងទៀតបើយើងមិនសប្បាយចិត្តនឹងបុគ្គលណាម្នាក់ សូមកុំស្អប់ដល់សង្គមឬវត្តអារាម ព្រោះអ្នកដែលកំពុងធ្វើការងារបន្តគឺជាអ្នករងគ្រោះ។

ដូច្នេះពុទ្ធបរិស័ទទាំងបួនជំពូកនេះហើយ ជាខ្លឹមនៃព្រះពុទ្ធសាសនា ត្រូវប្រកាន់យកសីលធម៌ ព្រហ្មវិហារធម៌ គុណធម៌ និងសង្គហធម៌ខ្ពស់ ទើបការផ្សាយឱវាទព្រះពុទ្ធបានជ្រៀបដល់បេះដូងមនុស្សទូទៅបាន។

ដោយយោងទៅតាមអត្ថប្រយោជន៍នេះហើយ ទើបព្រះសង្ឃ គណៈកម្មការ អាចារ្យវត្តខេមរង្សី រៀបចំពិធីបុណ្យវិសាខបូជានេះឡើង ជារៀងរាល់ឆ្នាំ ដើម្បីរំលឹកនឹកដល់នក្ខត្តឫក្សទាំងបី ដែលជាថ្ងៃមួយមានខ្លឹមសារនិងគុណប្រយោជន៍ សំរាប់អ្នកគោរពប្រតិបត្តិសាសនាព្រះ សូម្បីអង្គការសហប្រជាជាតិក៏គេទទួលស្គាល់និងឱ្យតំលៃចំពោះនក្ខត្តឫក្សទាំងបី គឺថ្ងៃដែលព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើងទ្រង់ប្រសូត, ទ្រង់ត្រាស់ដឹងនោះដែរ៕

*(តមកពីទំព័រទី១៩)* គឺមានន័យថា គាត់មិនមានដីធ្លីសំអាងដល់ការខ្ចីប្រាក់បានឡើយ ហើយភូមិឃុំបានចុះហត្ថលេខាឲ្យចំពោះតែអ្នកភូមិដែលមានសំអាង។ លោក ខៀវ សំបូរ បានអះអាងថា ៖ *«៨០%គ្មានខ្វះពូជដាំ ហើយវាងាប់អ៊ីចឹងណា! អាជ្ញាធរថា ឲ្យធ្វើប្លង់ដើម្បីនឹងឲ្យខាងអង្គការហ្នឹងទទួលស្គាល់ថា យើងមានប្លង់ដីប៉ុណ្ណេះៗ!»*។

អ្នកសម្របសម្រួលអង្គការសិទ្ធិមនុស្ស អាដហុក ខេត្តមណ្ឌលគិរី លោក សម សារិន បានថ្លែងថា វាជារឿងពីរផ្សេងគ្នា រវាងការវាស់ដំរឿនក្បាលដី និង ការខ្ចីប្រាក់ពីធនាគារ។ ដូច្នេះគួរតែអាជ្ញាធរជួយដោះស្រាយដល់ពួកគាត់ ប្រសិនបើពួកគាត់មានដីធ្លីរស់នៅប្រកបមុខរបរស្របច្បាប់ហើយនោះ។

នៅទូទាំងឃុំស្រែខ្ទុមមានប្រជាពលរដ្ឋសរុប២០៥០គ្រួសារមានដីចម្ការកំពុងប្រើប្រាស់ដាំដុះចំនួន ៨៦៧ ៥ហិកតារ។ ការដាំដំណាំ ពិសេសដំឡូងមី នៅដើមរដូវនេះបានខូចចំនួនបីលើកហើយ ដោយសារការរាំងស្ងួតធ្វើឲ្យកសិករជួបបញ្ហាខ្វះទុនទិញពូជដំណាំដាំដុះបន្ត៕

## កម្ពុជាទាមទារឱ្យថៃដោះលែងពលរដ្ឋខ្មែរ ដែលត្រូវចាប់ខ្លួន

មន្ត្រីកម្ពុជា នៅថ្ងៃចន្ទនេះ បានទាមទារឱ្យរដ្ឋាភិបាលក្រុងបាងកកដោះលែងពលរដ្ឋ របស់ខ្លួនមួយរូបដែលអាជ្ញាធរថៃបានចាប់ខ្លួន ក្រោមបទចោទ ប្រកាន់ថាបានដុតបំផ្លាញធនាគារមួយនៅទីក្រុងបាងកកក្នុងអំឡុងពេលមានការបង្ក្រាបក្រុមបាតុករកាលពីសប្តាហ៍មុន។ជាបន្តសូមស្តាប់របាយការណ៍របស់លោកសយ សុភាព ពីរាជធានីភ្នំពេញដូចតទៅ៖ អ្នកនាំពាក្យឲ្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង បានថ្លែងប្រាប់វិទ្យុអាស៊ីសេរីឱ្យដឹងថា ក្រសួងការបរទេសកម្ពុជាបានស្នើទៅប្រទេសថៃឱ្យមានការដោះលែងពលរដ្ឋកម្ពុជា ដែលត្រូវបានចាប់ខ្លួន ជាអ្វីដែលកម្ពុជាចាត់ទុកខ្លួនមិនទទួលយកបាននោះឡើយ ចំពោះការចោទប្រកាន់គ្មានមូលដ្ឋានរបស់រដ្ឋាភិបាលក្រុងបាងកក។ លោកកុយ គួង បានថ្លែងបញ្ជាក់ថា តាមពិតពលរដ្ឋខ្មែរម្នាក់នោះ បានរស់នៅដោយស្របច្បាប់ នៅក្នុងប្រទេសថៃ អស់រយៈពេលជាង៥ឆ្នាំមកហើយ ដោយបានរៀបការជាមួយភរិយាជនជាតិ ថៃនៅទី ក្រុងបាងកក។ លោកបានបន្ថែម បុរសខ្មែរម្នាក់នោះ មិនមានការជាប់ពាក់ព័ន្ធណាមួយទៅនឹងការដុតបំផ្លាញធនាគារណាមួយរបស់ថៃនោះទេ គ្រាន់តែបុរសនោះឈរពីទីតាំងហាងមួយដែលខ្លួនធ្វើការមើលអគារ ដែលរងការបំផ្លាញតែប៉ុណ្ណោះ។

ប្រតិកម្មរបស់អ្នកនាំពាក្យក្រសួងការបរទេសខ្មែររូបនេះ បានធ្វើឡើងក្រោយពេល ដែលរដ្ឋាភិបាលក្រុងបាងកក បាននិយាយថាពលរដ្ឋខ្មែរមួយរូបត្រូវបានចាប់ខ្លួនពីបទថា បានចូលរួមបំផ្លិចបំផ្លាញអគារធនាគារនៅទីក្រុងបាងកក នៅពេលដែលមានការបង្ក្រាបក្រុមបាតុករ ប្រឆាំងរដ្ឋាភិបាលរបស់នាយករដ្ឋមន្ត្រីអាប់ភីស៊ីតវ៉ាចាជីវ៉ា។

គួររំលឹកផងដែរ ទាំងលោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន និង ក្រសួងការបរទេសកម្ពុជា ក៏បានអំពាវនាវព្រមៗគ្នា មិនឱ្យប្រជាពលរដ្ឋខ្មែរណាមួយដែលកំពុងបំរើការងារនិងរស់នៅក្នុងប្រទេសថៃ ចូលរួមធ្វើបាតុកម្មណាមួយជាដាច់ខាត។ហើយក៏បានផ្តាំផ្ញើផងដែរឱ្យពលរដ្ឋទាំងនោះនៅឱ្យឆ្ងាយពីទីតាំងជួបប្រជុំណាមួយទោះក្រុម បាតុករ អាវពណ៌អ្វីក៏ដោយ។

ប៉ុន្តែទោះ ជាយ៉ាងណាក៏គេមិនឃើញប្រតិកម្មជាផ្លូវការណាមួយពីរដ្ឋាភិបាលក្រុងបាងកក នៅឡើយនោះទេ៕

*ប្រភព វិទ្យុអាស៊ីសេរី*

# លោកអូបាម៉ាបង្ហាញឱ្យដឹងនូវយុទ្ធសាស្ត្រអាមេរិកពាក់ព័ន្ធនឹងបញ្ហាសន្តិសុខជាតិ



*លោកប្រធានាធិបតីថ្លែងការនៅបណ្ឌិតសភាយោធា West Point*

ថ្លែងទៅកាន់នាយទាហាននៅបណ្ឌិតសភា យោធា West Point លោកប្រធានាធិបតីបារ៉ាក់អូបាម៉ាបានចង្អុលឲ្យដឹងនូវគោលនយោបាយយុទ្ធសាស្ត្រអាមេរិកពាក់ព័ន្ធនឹងបញ្ហាសន្តិសុខជាតិ ដែលនឹងត្រូវប្រកាសឲ្យដឹងជាសាធារណៈនៅពេលខាងមុខនេះ។ហើយអ្វីដែលគួរឲ្យកត់សម្គាល់គឺយុទ្ធសាស្ត្ររបស់លោកអូបាម៉ាមាន លក្ខណៈខុសពីយុទ្ធសាស្ត្រនៃប្រធានាធិបតីអាមេរិកមុនៗ។ ទល់នឹងទ្រឹស្តីនៃការធ្វើសង្គ្រាមដើម្បីការពារខ្លួននៅករណីដែលគេយល់ថាអាចមានការគំរាមដែលលោកអតីតប្រធានាធិបតី Geoerge W Bush បានថ្លែងនៅបណ្ឌិតសភាយោធា West Point នៅខែមិថុនាឆ្នាំ២០០២ លោកប្រធានាធិបតីបារ៉ាក់អូបាម៉ាបានថ្លែងប្រកាសឲ្យដឹងថា លោកនិយមរបៀបរបបអន្តរជាតិថ្មី"ជាង ទ្រឹស្តីនៃការធ្វើសង្គ្រាមដើម្បីការពារខ្លួនរបស់លោកអតីតប្រធានាធិបតី Geoerge W Bush ។របៀបរបបអន្តរជាតិថ្មី ដែលឈរលើគោលការណ៍សហប្រតិបត្តិការជាដៃគូជាមួយប្រទេសដទៃទៀតក្នុងលោកដើម្បីប្រយុទ្ធតទល់ ហើយនិងរិះរកដំណោះស្រាយឲ្យបញ្ហាសេដ្ឋកិច្ចបញ្ហាយោធានិងបញ្ហាដែលមាននៅជុំវិញខ្លួនយើង។

ទោះបីជាលោកអូបាម៉ាឲ្យអាទិភាពទៅលើការប្រើការទូតជាងការប្រើកម្លាំងយោធាដើម្បីដោះស្រាយវិបត្តិក៏ដោយ ក៏លោកអូបាម៉ាដឹងថា បច្ចុប្បន្ននេះសហរដ្ឋអាមេរិកមានសង្គ្រាមពីរនៅលើដៃរបស់ខ្លួន ហើយសហរដ្ឋអាមេរិកបានក្លាយជាផ្ទាំងស៊ីប្លឹនៃការប៉ុនប៉ងធ្វើភេរវកម្មដល់ទៅពីរលើកនារយៈ៥ខែចុងក្រោយនេះ។

ថ្លែងទៅកាន់នាយទាហានជំនាន់ឆ្នាំ២០១០ លោកអូបាម៉ាបានសន្យានឹងផ្តល់ការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់ប្រជាជាតិដែលមានមោទនភាពយ៉ាងខ្ពង់ខ្ពស់។លោកអូបាម៉ាបានថ្លែងទៅកាន់យុវនាយទាហានទាំងនោះថា សង្គ្រាមនៅអាហ្វហ្គានិស្តង់គឺ ជាសង្គ្រាមមួយដ៏លំបាកក៏ប៉ុន្តែនៅទីបំផុតគឺយើងជាអ្នកបានទទួលជោគជ័យ។ ពាក់ព័ន្ធនឹងប្រទេសអៀរ៉ាក់វិញ លោកអូបាម៉ាយល់ថា ក្រោយពីការចាកចេញនៃយោធាអាមេរិក ប្រទេសអៀរ៉ាក់នឹងក្លាយទៅជាប្រទេសមួយដែលស្គាល់ស្ថិរភាព អធិបតេយ្យភាព និងស្វ័យភាពគ្រប់គ្រាន់៕

# ប្រេងឆៅ ដែលធ្លាយពីឈូងសមុទ្រម៉ិចស៊ិកបានប៉ះពាល់តំបន់ឆ្នេរសមុទ្ររដ្ឋ Louisiana



តំបន់ឆ្នេរសមុទ្រនៅរដ្ឋ Louisiane សហរដ្ឋអាមេរិក

ការផ្ទុះស្ថានីយ៍បូមប្រេងមួយ របស់ក្រុមហ៊ុនប្រេងឥន្ធនៈអង់គ្លេសឈ្មោះBpនៅឈូងសមុទ្រMexicoue កាលពីសប្តាហ៍មុន បានធ្វើឲ្យប្រេងឆៅធ្លាយចេញអណ្តែតរសាត់ពាសពេញទឹកសមុទ្រ។ប្រេងឆៅបានអណ្តែតរសាត់ទៅដល់ឆ្នេរសមុទ្រនៃរដ្ឋLouisiana សហរដ្ឋអាមេរិក។ ជាព្រឹត្តិការណ៍មួយដែលបានជម្រុញឲ្យរដ្ឋាភិបាលប្រកាសចាត់ទុក............( *តទៅទំព័រទី២៤*)



ប្រេងឆៅអណ្តែតលើទឹកសមុទ្រប្រវែង៩០០គីឡូម៉ែត្រ

*(តមកពីទំព័រទី២៣)* ជាគ្រោះមហន្តរាយជាតិ។

បើយោងតាមអ្នកឯកទេសខាងបរិស្ថានប្រេងឆៅ ដែលបានធ្លាយចេញពីការផ្ទុះស្ថានីយ៍បូមប្រេងមួយរបស់ក្រុមហ៊ុនប្រេងឥន្ធនៈអង់គ្លេសឈ្មោះ BP នៅឈូងសមុទ្រម៉ិកស៊ិកកាលពីសប្តាហ៍មុន គឺជាមហន្តរាយមួយ ដែលនឹងអាចផ្តល់ផលអាក្រក់ជាងការផ្ទុះស្ថានីយ៍បូមប្រេង Exxon Valdez នៅក្នុងរដ្ឋអាឡាស្កា កាលពី ២៥ឆ្នាំ មុនទៅទៀត។ កាលណោះ ប្រេងឆៅ ដែលធ្លាយចេញពីការផ្ទុះនោះបានអណ្តែតរសាត់តាមបណ្តោយឆ្នេរប្រវែងជាង ២០០០ គីឡូម៉ែត្រ។ ករណីផ្ទុះស្ថានីយ៍បូមប្រេង Exxon Valdez កាលពី ២៥ឆ្នាំមុនគឺមានតែប្រេងឆៅស្តុកនៅក្នុងស្ថានីយ៍នោះប៉ុណ្ណោះដែលបានធ្លាយហូរចាក់លើផ្ទៃសមុទ្រ។ ចំណែកឯការផ្ទុះស្ថានីយ៍បូមប្រេងនៅឈូងសមុទ្រម៉ិកស៊ិក នាពេលនេះមាន២ករណីទីមួយៈ គឺការធ្លាយប្រេងឆៅដែលស្តុកនៅស្ថានីយ៍ប្រមាណជា ៤ម៉ឺនម៉ែត្រគូប និងទីពីរ ដែលជាក្តីបារម្ភខ្លាំងជាងគេនោះ គឺមានបរិមាណប្រេងឆៅជាង ៨០ម៉ឺនលីត្រ កំពុងបន្តបាញ់ចេញជារៀងរាល់ថ្ងៃ ពីប្រភពនៅបាតសមុទ្រ ក្នុងជម្រៅ ១ គីឡូម៉ែត្រ កន្លះ។ខណៈនេះ គេកំពុងគិតគូរកមធ្យោបាយ ដើម្បីបិទខ្ទប់ប្រភពប្រេងនោះ។ តាមធម្មតា គេត្រូវការពេលវេលាជាច្រើនសប្តាហ៍ឬច្រើនខែផង។ ឧប្បត្តិហេតុដូចគ្នានេះ បានកើតមានម្តងហើយ នៅក្នុងប្រទេសអូស្ត្រាលីក្នុងឆ្នាំ ២០០៩។ កាលណោះ គេបានចំណាយពេលរហូតដល់ទៅ៧០ថ្ងៃទើបអាចបិទរន្ធប្រភពប្រេងកុំឲ្យបាញ់ចេញមកក្រៅ។ ផលវិបាកដែលជះលើរដ្ឋ Louisiana គឺវិស័យបរិស្ថាន។ នៅរដ្ឋ Louisiana បញ្ហាបរិស្ថានជារឿងមួយដែលគេមិនអាចធ្វើព្រងើយកន្តើយបានឡើយ ពីព្រោះជាតំបន់ពិសេសមួយ ដែលសម្បូរទៅដោយជីវៈចម្រុះ មានទាំងសត្វនិងរុក្ខជាតិគ្រប់បែបយ៉ាង។ ដូច្នេះ វាជារឿងមួយបន្ទាន់បំផុត ដែលរដ្ឋាភិបាលត្រូវចាត់វិធានការទប់ទល់ ព្រោះថា ប្រេងឆៅដែលអណ្តែតលើផ្ទៃទឹកសមុទ្រ និងដែលទៅបៀមជាប់នឹងដីនោះអាចសម្លាប់សត្វសមុទ្រនិងបំផ្លាញរុក្ខជាតិគ្រប់ប្រភេទ។ក្រុមសង្គ្រោះបន្ទាន់បានប្រើពោងបណ្តែត ដើម្បីកៀងប្រមែប្រមូលផ្តុំប្រេងឆៅ កុំឲ្យរសាត់អណ្តែតពាសវាលពាសកាលធំពេក។ ប៉ុន្តែវិធានការនេះ ហាក់ដូចជាគ្មានប្រសិទ្ធិភាពប៉ុន្មានទេ ព្រោះថាពេលនេះ ប្រេងឆៅកំពុងរសាត់អណ្តែតលើផ្ទៃទឹកសមុទ្រប្រមាណជា១៥០០គីឡូម៉ែត្រក្រឡា និងកំពុងតែបន្តលាតសន្ធឹង កាន់តែធំទៅៗ។ វិធានការបន្ទាប់មកទៀតគេបានដុតប្រេងឆៅនៅលើផ្ទៃទឹកសមុទ្រនោះតែម្តង។ វិធានការដុតនេះ មិនត្រូវបានគ្រប់ប្រទេសយកទៅអនុវត្តទេ ហើយបើតាមការយល់ឃើញរបស់ក្រុមអ្នកការពារបរិស្ថាន គេមិនត្រូវយកទៅប្រើទេ ពីព្រោះថា ការដុតប្រេងឆៅបានបញ្ចេញជាផ្សែងយ៉ាងខ្មួលខ្មាញ់ ដែលបង្កប់ទៅដោយសារជាតុគីមី នាំឲ្យកើតជំងឺមហារីក ដូចគ្នានឹងផ្សែងបារី។ មួយវិញទៀត សារជាតុគីមី ដែលនាំឲ្យកើតជំងឺមហារីកនេះ មិនមែនមានតែនៅក្នុងផ្សែងនោះប៉ុណ្ណោះទេ តែក៏មាននៅក្នុងកាកសំណល់ប្រេងឆៅដែលមិនឆេះ និងនៅក្នុងទឹកដែរ៕



ប្រតិបត្តិការបោសសំអាតប្រេងឆៅនៅលើផ្ទៃទឹកសមុទ្រ

# ស្លឹកតើយមានក្លិនក្រអូបជួយឱ្យមានសុខភាពល្អ



ស្លឹកតើយជារុក្ខជាតិពពួកស្មៅដែលដុះលូតលាស់បែកចេញជាគុម្ពធំៗមានឫសគល់ និងដើមដែលមានធាង និងស្លឹកបែកសាខានៅលើដី។ ស្លឹកវាមានពណ៌បៃតង រាងទ្រវែងស្រួចនៅខាងចុង ប្រវែងប្រហែលពី ៨ទៅ១០អ៊ីញ ។ ក្នុងខណៈពេលយកស្លឹកស្រស់ទៅឈ្លីវាមានក្លិនក្រអូប គេនិយមយកក្លិនចេញពីស្លឹកវាទៅដាក់នៅលើនំចំណីនានាឱ្យមានក្លិនក្រអូបប្រហើរគួរឱ្យចង់ទទួលទានស្លឹកតើយផ្ទុកទៅដោយសារជាតុប្រេងក្រអូប មានគុណតំលៃលើម្ហូបអាហារ មានសារជាតុក្លរ៉ូហ្វីល ជួយកាត់បន្ថយអាការស្រេកទឹក ជួយទ្រទ្រង់បេះដូង និងធ្វើឱ្យមានភាពស្រស់ស្រាយ។ ក្រៅពីនេះវាក៏មានសារជាតុអំបិលខនិជ និងកាល់ស្យូម ឯឫសរបស់វាប្រើប្រាស់ធ្វើជាថ្នាំឱ្យបត់ជើងតូច(ជុះនោម) បានស្រួលឬក៏ប្រើសំរាប់ព្យាបាលជំងឺទឹកនោមផ្អែម។ សំរាប់ស្លឹកតើយស្រស់អាចយកមកព្យាបាលរោគរមាស់សើរស្បែកផងដែរ ។

ក្រៅពីនេះប្រសិនបើយកស្លឹកតើយខ្ចីស្រស់ចំនួន៤សន្លឹកនិងស្លឹករាងទុំ៨សន្លឹក ស្ងោររម្ងាស់ជាមួយទឹក១លីត្រ រយៈពេល ១៥នាទី រួចពិសាក្នុងពេលក្តៅអ៊ុនៗ កន្លះកែវទាំងពេលព្រឹកថ្ងៃនិងល្ងាចនឹងជួយបណ្តេញជាតិកំបោរនៅតាមសន្លាក់ដៃជើងអាចឱ្យយើងដើរបានស្រួល ដោយមិនមានការឈឺតាមសន្លាក់ហើយវាក៏ជាប្រភេទឱសថជួយលាងជាតិពុលក្នុងរាយកាយផងដែរ។ លោកអ្នកត្រូវស្ងោររម្ងាស់ពិសាបន្តបន្ទាប់គ្នារយៈពេល៣ថ្ងៃ រំលងបាន១សប្តាហ៍ទើបស្ងោរពិសាបន្តបើលោកអ្នកធ្វើបែបជារឿយៗគឺរាងកាយរបស់អ្នកនឹងមានសុខភាពល្អមិនខាន៕

# ក្រូចឆ្មារកំពូលថ្នាំបញ្ចុះទម្ងន់ដែលល្អជាទីបំផុត



ក្រូចឆ្មារត្រូវទុកដូចប្រភេទថ្នាំម៉្យាងដែលមានគុណសម្បត្តិ ក្នុងការជួយបញ្ចុះភាពធាត់បានយ៉ាងល្អជាទីបំផុត បើលោកអ្នកធ្វើតាមប្រការទាំង៣ចំនុចដូចខាងក្រោមនេះ លោកអ្នកនឹងបញ្ចុះទម្ងន់ដូចចិត្តប្រាថ្នា៖

**១.ផឹកទឹកក្រូចឆ្មាជាមួយទឹកក្តៅឧណ្ហៗរាល់ព្រឹក:**

ដើម្បីជំរុញរបបរំលាយអាហារឲ្យធ្វើការកាន់តែប្រសើរឡើង ក្រូចឆ្មារជាផ្លែឈើដែលមានវីតាមីនCច្រើនជាទីបំផុតមិនត្រឹមតែល្អសម្រាប់ជួយបញ្ចុះជាតិខ្លាញ់ប៉ុណ្ណោះទេតែវានៅមានប្រយោជន៍ជួយជំរុញរបបរំលាយអាហារបានល្អនិងជួយបញ្ចុះទម្ងន់បានល្អជាងវិធីផ្សេងៗថែមទៀតផង នេះជាលទ្ធផលស្រាវជ្រាវពីមហាវិទ្យាល័យ Arizona សហរដ្ឋអាមេរិក ព្រោះទឹកក្រូចឆ្មារជួយឲ្យរាងកាយស្រូបជញ្ជក់ជាតិកាល់ស្យូម បង្ខាំងទុកក្នុងកោសិកាខ្លាញ់ដែលធ្វើឲ្យជាតិកាល់ស្យូមមាននៅក្នុង*(តទៅទំព័រទី២៨)*

# ការស្រាវជ្រាវនៅអូស្ត្រាលី បង្ហាញថាឆ្នាំ២៣00ខាងមុខ ផែនដីនឹងឡើងកំដៅមិនអាច ឱ្យមនុស្សរស់នៅបានទៀតទេ

លទ្ធផលស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្រ អូស្ត្រាលីបញ្ជាក់ថា ការផ្លាស់ប្តូរស្ថានភាព អាកាសធាតុអាចធ្វើឱ្យផែនដីមានកំដៅខ្លាំង ជាងអាកាសធាតុដែលមនុស្សរស់នៅបានក្នុង រយៈពេល៣សតវត្សខាងមុខ។ ក្រុមអ្នកវិទ្យាសាស្ត្រមកពីមហាវិទ្យាល័យញូវសៅវ៉េល ប្រទេសអូស្ត្រាលី និងមហាវិទ្យាល័យភើឌូ ក្នុងសហរដ្ឋអាមេរិក សិក្សាស្រាវជ្រាវឃើញថា សីតុណ្ហភាពដែលកើនឡើងនៅតាមតំបន់ខ្លះ អាចធ្វើឱ្យមនុស្សមិនអាចសំបេខ្លួនបានឬមានជីវិតរស់នៅបាន។ ការងារស្រាវជ្រាវនេះបញ្ជាក់ឱ្យដឹងថា ស្ថានភាពខាងលើនឹងឡើងខ្ពស់ជាងសីតុណ្ហភាព ប្រក្រតីប្រហែល៧អង្សាសេ ដែលអាចធ្វើឱ្យភូមិភាគខ្លះមិនអាចរស់នៅបាន ។

លោកសាស្ត្រាចារ្យស្ទីវ៉េន ឈ័រវូដ មនុស្សម្នាក់ក្នុងចំណោមអ្នកស្រាវជ្រាវឱ្យដឹងថា គ្មានឱកាសដែលផែនដីនឹងកើនកំដៅដល់ ៧អង្សាសេ នៅក្នុងសតវត្សនេះប៉ុន្តែក៏មានភាពប្រថុយប្រថានក្នុងការកើតភ្លើងឆេះកល្បដែលនឹងកើតឡើងនៅក្នុងឆ្នាំ២៣០០ ការសិក្សាស្រាវជ្រាវនេះ បានធ្វើការត្រួតពិនិត្យការប្រែប្រួលអាកាសធាតុក្នុងរយៈពេលយូរជាងការស្រាវជ្រាវផ្សេងៗ ទៀតភាគច្រើនបានសិក្សាទៅលើកំដៅដែលកើតពីផលប៉ះពាល់នៃសីតុណ្ហភាព និងសារធាតុ ដែលបង្កើនកំដៅកាន់តែខ្ពស់ជាដើម ហេតុនៃស្ថានភាពកំដៅផែនដី។

លោកឈ័រវូដ បានបន្តទៀតថា មនុស្សធ្វើអ្វីៗមិនបានច្រើនទាក់ទិននឹងការប្រែប្រួលអាកាសធាតុក្នុងរយៈពេល២សតវត្សខាងមុខ ប៉ុន្តែនៅមានវត្ថុ ដែលយើងអាចធ្វើបានជាច្រើនទៀតសំរាប់បំរែបំរួលក្នុងរយៈពេលវែង។ លើសពីនេះ ការបង្ហាញគំនិតយល់ឃើញរបស់ការងារស្រាវជ្រាវនេះ ដែលរក្សាទុកធ្វើជាឯកសារនៅក្នុងមហាវិទ្យាល័យជាតិអូស្ត្រាលីបានបញ្ជាក់ថាការប្រែប្រួលអាកាសធាតុនឹងមិនបញ្ឈប់នៅត្រឹមឆ្នាំ២១០០



ស្ថានភាពទឹកកកកំពុងចាប់ផ្តើមកកតាមផ្ទៃសមុទ្រ



ស្ថានភាពទឹកកកកំពុងរលាយយ៉ាងឆាប់រហ័ស

ទេ ប៉ុន្តែចាប់ពីឆ្នាំ២៣០០តទៅ សីតុណ្ហភាពអាចកើនខ្ពស់ដល់ទៅ១២អង្សាសេ ឬច្រើនជាងនេះ។

ចំណែកលោកសាស្ត្រាចារ្យថូនី ម៉េកម៉ៃឃើល មនុស្សម្នាក់ ក្នុងចំណោមក្រុមអ្នកស្រាវជ្រាវនេះឱ្យដឹងថា *«ប្រសិនបើបញ្ហានេះ កើតឡើងភ្លាមៗក្នុងពេលបច្ចុប្បន្ន របស់យើងទាក់ទិននឹងកំរិតទឹកសមុទ្រឡើងខ្ពស់លេកកំដៅនិងភ្លើងឆេះព្រៃដែលកើតឡើងការបាត់បង់ផ្នែកជីវសាស្ត្រជាច្រើន និង ក្តីលំបាកក្នុងផ្នែកកសិកម្មនឹងចុះខ្សោយហេតុគ្មានសារសំខាន់ក្នុងពេលប្រៀបធៀបនឹងគ្រោះថ្នាក់ដ៏ធំ ដែលនៅតំបន់ច្រើនជាងពាក់កណ្តាលនៃផែនដីយើងរស់នៅនាពេលបច្ចុប្បន្ន អាចក្តៅហេតុធ្វើឱ្យមនុស្សមិនអាចរស់នៅបាន»*។

# ហាងមាសមេគង្គ

## 湄江 MEKONG JEWELRY 珠寶



- **មានលក់មាសនិងពេជ្រគ្រប់ប្រភេទ**
- មានលក់គុជនិងត្បូងពេជ្រជាច្រើនសម្រាប់ធ្វើជាខ្សែក, ខ្សែដៃ, ក្រវិលនិងចិញ្ចៀន។ល។
- ទទួលរចនាគ្រឿងអលង្ការគ្រប់មុខគ្រប់ម៉ូដតាមការនិយមចូលចិត្តបែបបុរាណឬសម័យ។
- ទទួលជួសជុលគ្រឿងអលង្ការភ្លាមៗ !!!

សូមស្វាគមន៍អតិថិជនគ្រប់ទិសទី !!!

- **All Kinds of Diamonds & golds**
- COUNTLESS OF STYLES AVAILABLE FOR RINGS, NECKLACE, BRACELETS, ETC.
- WE ACCOMODATE ANY DESIGN THAT BEST SUITS YOUR INTERESTS.
- WE ARE MORE THAN HAPPY TO FIX OR REDESIGN YOUR PREOWNED JEWELRY.
- A VISIT TO OUR STORE WILL GUARANTEE YOUR SATISFACTIONS.

ADDRESS:
1954 ABORN ROAD
SAN JOSE, CA 95121

KIM
TEL: (408) 238-3377
FAX: (408) 238-2601

## ក្រុមហ៊ុនលក់សំបុត្រយន្តហោះTravel Rose

- មានលក់សំបុត្រយន្តហោះក្នុងនិងក្រៅប្រទេស
- មានទទួលធ្វើទិដ្ឋាការទៅ អាស៊ី, អឺរុប, អូស្ត្រាលី និងប្រទេសផ្សេងៗនៅជុំវិញពិភពលោក។
- មានទទួលធ្វើលិខិតឆ្លងដែន
- **Airline Ticket, Re-entry Permit, Visa, Passport**

សូមអញ្ជើញទំនាក់ទំនងមកក្រុមហ៊ុនយើងខ្ញុំដោយមេត្រីភាព តាមអាស័យដ្ឋានដូចខាងក្រោម

| Travel Rose<br>Travel &Tour<br>ANH(THANH)V0 | 639 Tully Road Suite<br>San Jose, CA 95111<br>Tel: (408) 971-4530 |
|---|---|





*(តមកពីទំព័រទី២៥)* កោសិកាខ្លាញ់បរិមាណច្រើន នឹងជួយដុតបំផ្លាញខ្លាញ់បានល្អជាទីបំផុត ។

**២.ទទួលទានបន្លែនិងផ្លែឈើយ៉ាងតិច១ថ្ងៃ៥ប្រភេទ៖**

បន្លែ និងផ្លែឈើគ្រប់ប្រភេទ នឹងមានបរិមាណកាឡូរីតិច ឬច្រើន តែវាមានឧត្តមភាពទៅដោយវីតាមីន ជាតុរ៉ែ,ជាតិសរសៃ ដែលនឹងជួយឲ្យមានតុល្យភាពអ័រមូន នៅក្នុងរាយកាយ និងជួយឲ្យរបបសរសៃប្រសាទធ្វើការបានយ៉ាងស្ងប់អារម្មណ៍ ។

**៣.ធ្វើឲ្យមានតុល្យភាពលំដាប់ជាតិស្ករក្នុងឈាម៖**

ដោយការប្រេបាច់ទឹកក្រូចឆ្មារ ចូលទៅក្នុងអាហាររាល់ពេលទទួលទាន ឬផ្សំសម្បកក្រូចឆ្មារចូលទៅក្នុងទឹកស៊ុប ហើយយើងអាចយកក្រូចឆ្មារប្រេបាច់នៅលើសាច់ត្រី ឬសាច់មាន់, សាច់គោ បន្តិចបន្តួច មុនពេលទទួលទានយើងមានអារម្មណ៍ថា ក្រូចឆ្មារ គឺមានរសជាតិអស្ចារ្យជាទីបំផុត មិនតែប៉ុណ្ណោះក្រូចឆ្មារ ដែលប្រេបាច់ចូលជាមួយសាច់ ពេលទទួលទាននោះ វានឹងជួយបញ្ចុះជាតិស្ករនៅក្នុងឈាមបានល្អជាទីបំផុត ៕

## ឥទ្ធិពលអវិជ្ជមាននៃម៉ាស៊ីនត្រជាក់ចំពោះបរិស្ថាន




ម៉ាស៊ីនត្រជាក់សំភារៈឧបករណ៍នៅក្នុងផ្ទះ ដែលមិនអាចខ្វះបានសំរាប់អ្នកមាន។ ម្យ៉ាងទៀត វាត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងកន្លែងសំខាន់ៗ ដូចជាស្ថាប័នកំពូលរបស់រដ្ឋ និងកន្លែងធ្វើការធំៗ។ មានមនុស្សមួយភាគដែលប្រើម៉ាស៊ីនត្រជាក់ មិនទាំងដឹងខ្លួនថាកំពុងតែរួមចំនែក បំពុលបរិស្ថាននោះទេ។

ម៉ាស៊ីនត្រជាក់ចូលរួមចំណែកជាមួយនិងសំរាប់ប្រើប្រាស់ប្រចាំថ្ងៃមួយចំនួនទៀតដូចជាទូទឹកកកនិងSprayបាញ់ខ្លួនដើម្បីផលិតឧស្ម័នបំពុលបរិស្ថានម្យ៉ាងឈ្មោះក្លរួភ្លុយអរូកាបោន (Chlorofluorocarbons) ហៅកាត់ថា CFCs។ ឧស្ម័ន CFCs ធ្វើអោយស្រទាប់បរិយាកាសអូសូនដែលការពារផែនដីពីកាំរស្មីស្វាយអ៊ុលត្រាពីព្រះអាទិត្យកាន់តែស្តើងទៅៗ។ ចាប់តាំងពីឆ្នាំ១៩៧៨មក ការបញ្ចេញឧស្ម័ននេះតាមរយៈកំប៉ុងSpray ត្រូវបានរដ្ឋាភិបាលអាមេរិកនិងកាណាដាហាមឃាត់។ សំភារៈទាំងនេះនៅតែមានការប្រើប្រាស់ក្នុងចំនួនដ៏ច្រើន ដែលរួមចំនែក ២៥%នៃការបញ្ចេញ CFCs ទាំងមូល។ តាមការស្រាវជ្រាវលក្ខណៈវិទ្យាសាស្ត្រមួយបានបង្ហាញថា ឧស្ម័នពុលចេញពីការប្រើប្រាស់ឧបករណ៍ទាំងនេះនឹងស្ថិត នៅក្នុងបរិយាកាសផែនដីរយៈពេលពី២២ទៅ១១១ឆ្នាំ។ យើងអាចនិយាយបានថាក្លរួភ្លុយអរូកោននេះធ្វើដំណើរទៅក្នុងស្រទាប់បរិយាកាសរាប់សិបទសវត្សងណោះ។ ក្រោមឥទ្ធិពលកាំរស្មីស្វាយអ៊ុលត្រាដ៏ខ្លាំងស្រទាប់អូសូន ($O_3$) អាចផ្តាច់ខ្លួនទៅជាអុកស៊ីសែន($O_2$)។ CFCs ក៏ត្រូវបានគេស្គាល់ថាជាឧស្ម័នផ្ទះកញ្ចក់ដ៏សំខាន់មួយដែលរួមវិភាគទានក្នុងការឡើងកំដៅរបស់ផែនដី(global warming)ការសិក្សាផ្នែកឥទ្ធិពលគីមីរបស់វាលើការបំពុលបរិយាកាសត្រូវបានគេសំដៅយកអ័ព្ទបរិយាកាស(Smog)។សូមបញ្ជាក់ថា តាមប្រវត្តិសាស្ត្រម៉ាស៊ីនត្រជាក់ត្រូវបានគេដាក់អោយប្រើជាលើកដំបូងនៅឆ្នាំ១៨២០ ដោយអ្នកច្នៃប្រឌិតវិទ្យាសាស្ត្រ ម៉ៃយរ ផារ៉ាដាយ របស់ចក្រភពអង់គ្លេស។ ដូចនេះ ម៉ាស៊ីនត្រជាក់រួមចំណែកបំពុលចាប់តាំងពីជិត២០០ឆ្នាំមុនមកម្ល៉េះ៕ *ឯកសារស្រាវជ្រាវ*

*(តមកពីទំព័រទី១៩) របស់លោកប៉ិណ្ណ ចន្ទម៉ុល»* ដែលជាសមាជិកម្នាក់ដ៏សំខាន់ នៃក្រុមបដិវត្តន៍ បានសរសេរយ៉ាងច្បាស់លាស់ថា ដោយពួកទាហានខ្មែរដែលបានមកទាក់ទងជាមួយលោកគ្រូអាចារ្យ **ហែម ចៀវ** និងលោក **នួន ឌួច** នោះ មានទាហានខ្លះ ដែលស្រឡាញ់បារាំងដុះស្លែក្នុងខួរដុះមិនជ្រះនោះ វានាំរឿងសំលាប់នេះទៅប្រាប់បារាំងថា លោក អាចារ្យ **ហែម ចៀវ** និងលោក **នួន ឌួច** ជាមេដឹកនាំពួកទាហានខ្មែរអោយបះបោរប្រឆាំងនឹងបារាំង។ ទាហានខ្មែរចំនួន១៥ នាក់ ត្រូវចាប់ស្ងាត់ៗ ដើម្បីកុំអោយបែកការណ៍។ នៅថ្ងៃ១៧ កក្កដា ១៩៤២ ស្រាប់តែឃើញចាងហ្វាងគិញបារាំងម្នាក់ និងលេខាធិការខ្មែរពីរនាក់ទៀត មានកាន់សំណុំលិខិតមួយដុំផង បានទៅជួបលោក **អ៊ឹម អ៊ី** នាយករដ្ឋមន្ត្រី ព្រមទាំងលោក **ឆា សាន** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ធម្មការ និង មន្ត្រីឯទៀត ។ គ្រានោះ លោក **ឆា សាន** បានបញ្ជាលោក **ជុំ មួច** *(កាលណោះធ្វើជាលេខាធិការក្រោមបង្គាប់លោក)* អោយទៅនិមន្តលោកគ្រូអាចារ្យ **ហែម ចៀវ** មក។ លោក **ជុំ មួច** នឹកប្រហែលជាមានការធំហើយ ក្នុងរឿងសំងាត់ជាមួយគ្នា តែចាប់លោកគ្រូអាចារ្យ **ហែម ចៀវ** ទៅនឹងរាលដាលដល់អាត្មាអញមិនខាន ប៉ុន្តែពុំទាន់ដឹងច្បាស់ជារឿងអ្វីដែរ ? ដោយពុំហ៊ានសួរគេ ។លោក **ជុំ មួច** ក៏ទៅវត្តឧណ្ណាលោម និមន្តលោកគ្រូ **ហែម ចៀវ** លោកក៏បាននិមន្តជាមួយគ្នាជាបន្ទាន់ ។ តាមផ្លូវ លោកក៏បានសួរលោក **ជុំ មួច** ពីដំណើរដែលលោករដ្ឋមន្ត្រីអោយមកនិមន្តនេះ ។ លោក **ជុំ មួច** ក៏ទូលលោកតាមដំណើរ ដែលបានឃើញតែពុំដឹងជារឿងអ្វី។ លោកមានថេរដីកាថា បើវាសួរពីរឿងយើង យើងឆ្លើយប្រកែកថា តែពុំបានដឹងទៅ! រួចលោក មានថេរដីកាតមកទៀតថា លោក**សឺង ង៉ុកថាញ់** បានផ្តាំថា បើបារាំងវាដឹងរឿង ត្រូវអោយប្រញាប់រត់ចូលទៅឯមន្ទីរកងអាវុធហត្ថជប៉ុនជាប្រញាប់ទើបរួចខ្លួន! យោបល់ទាំងពីរនាក់យល់ថា ច្បាស់ជាបារាំងវាដឹងរឿងសំងាត់ហើយ ប៉ុន្តែពុំបានគិតដល់រឿងអ្វីទេ នឹកថាប្រហែលជាវាគ្រាន់តែហៅសួរសិនតែប៉ុណ្ណោះទេយ៉ាងមើល ?លុះលោកគ្រូអាចារ្យ **ហែម ចៀវ** ទៅដល់ ស្រាប់តែលោក **ឆា សាន** ប្រើអោយបំរើទៅទិញខោ១ អាវ១ មកហើយបង្ខំលោកគ្រូអាចារ្យ **ហែម ចៀវ** អោយផ្លាស់ស្បង់ចីពរពីខ្លួន ហើយស្លៀកពាក់ខោអាវភ្លាមរួចបារាំងវានាំទៅតាមរថយន្តវាបាត់ទៅតែម្តង។ រកតែរត់ទៅប្រាប់អ្នកណាក៏មិនទាន់ ។ គិតទៅពួកគេចាប់លោកផ្សឹកទាំងឥតជំនុំសោះ ។ មានចាស់ៗខ្លះបាននិយាយថា អាចារ្យ **ហែម ចៀវ** ដែលត្រូវបារាំងចាប់នេះ មកពីស្តេចសីហនុខ្សឹបអោយបារាំងចាប់ ទើបបានជាពួកវាដឹង ។ ស្តេច**សីហនុ** ខ្លាចក្រុមបដិវត្តន៍រំលាយរាជបល្លង្គចោលទើបធ្វើដូច្នេះ។ លោក **ជុំ មួច** កាន់តែភ័យខ្លាំងថា អញច្បាស់ជាបារាំងវាចាប់ខ្លួនទៀតជាពុំខាន។ លុះដល់ពេលចេញពីធ្វើការ ក៏ទៅជំរាប លោក **សឺង ង៉ុកថាញ់** តាមដំណើរ។ លោកក៏ប្រាប់ថា អោយប្រយ័ត្នខ្លួនអោយមែនទែន បារាំងប្រាកដជាចាប់យើងហើយ។ រឿងចាប់លោកគ្រូអាចារ្យ **ហែម ចៀវ** ក៏ផ្អើលឆោឡោឡើង ក្នុងបន្តាពួកលោកសង្ឃជានិស្សិតនៃសាលាបាលីជាន់ខ្ពស់និង វត្តនានាក្នុងក្រុងភ្នំពេញ ដែលច្រើនតែជាមិត្តភ័ក្តិនិងជាសិស្សរបស់លោក ។.....*(តទៅលេខក្រោយ)*


## ប្រេងខ្យល់ប្រទាលខ្មែរបុរាណ

**វិធីប្រើ៖** លាបនៅពេលដែលចុកដៃជើង, ស្ពឹកស្រពន់, ចុកចង្កេះ, ថ្លោះគ្រិច, ឈឺក្បាល, វិលមុខ, ពុលឡានពុលកាណូត, ពុលយន្តហោះ, ចុកពោះ, ឆ្អល់ពោះ, ហើមពោះ, ណែនពោះ, តឹងច្រមុះ, ផ្តាសាយ, មូសខាំ, ក្អែបខាំស្រាំងទិច, ឱម៉ាលទិច, ឡើងកន្ទួល, រម៉ាស់ផ្សេងៗ......។ **បញ្ជាក់៖** *ហាមយកប្រេងខ្យល់នេះទៅលាបភ្នែក។*

***លោក អ្នក ចង់បានប្រេងខ្យល់ប្រទាលខ្មែរបុរាណ សូមទំនាក់ទំនងទូរស័ព្ទលេខ៖ (408) 923-2166***

# កុំចេះតែចង់ គ្មានប្លង់កុំទៅ

ដោយ គុយ សុធន

បានអានបានស្តាប់សារសព្វវែងខ្លី ពាក្យពេចន៍មានន័យសម្តីទឹកឃ្មុំ
ផ្អែមល្ហែមរៀបរាប់បង្កប់អប់រំ ធម៌ព្រះពាក្យព្រហ្មចាស់ទុំទូន្មាន។
ថាកុំចង់បានរបស់ដែលអត់ ហេតុមិនប្រាកដកុំចង់បំពាន
កុំងាប់ចិត្តនឹងរបស់ដែលមាន អ្វីទាំងប៉ុន្មានពុំមានខ្លឹមសារ។
ព្រោះអ្វីកើតឡើងមានហេតុបច្ច័យ ពេលហេតុអស់ថ្លៃលត់សង្ខារ
កើតហើយអស់ទៅជារឿងធម្មតា ជរាពិការជាអ្នកកំដរ។
គ្មានអ្វីដែលល្អសំរាប់យើងឡើយ គឺយើងនេះហើយដែលជាមនុស្សល្អ
ប្រព្រឹត្តប្រតិបត្តិតាមផ្លូវព្រះធម៌ ជីវិតបវរទទួលជោគជ័យ។
ជីវិតជាការតស៊ូប្រឹងប្រែង អប់រំខ្លួនឯងតាមធម៌វិន័យ
កុំអស់សង្ឃឹមគិតតែពីភ័យ ត្រូវខំលកលៃតាមតួនាទី។
ជីវិតជាការប្រឹងប្រែងប្តូរផ្លាស់ ពីក្មេងទៅចាស់ជរាញាំញី
ចុងក្រោយគឺស្លាប់ចោលលើប្រឹថពី ចំណីធរណីចោលកូនរហង់។
ជីវិតប្រៀបដូចជាការដើរផ្លូវ ព្រះធម៌គង់នៅប្រៀបដូចជាប្លង់
ផែនទីនៅមានម្តេចមិនតម្រង់ ដើរវិលឥតប្លង់កុំចង់ដល់ឆាប់។
ភ្លឺណាស់ច្បាស់ណាស់ព្រះសទ្ធម្មថ្លៃ អស់ក្តីសង្ស័យក្រោយពីបានស្តាប់
ប្រៀបដូចបើកផ្ការបស់ដែលផ្កាប់ ឬដូចគេប្រាប់អ្វីដែលកំបាំង។
ដូចបង្ហាញផ្លូវដល់អ្នកវង្វេង ដែលដើរផ្សងព្រេងឱ្យដល់ទីតាំង
ឬដូចគេទ្រោលប្រទីបបញ្ចាំង ទីងងឹតខ្លាំងឱ្យមានរស្មី។
អ្នកមានភ្នែកភ្លឺអាចយល់សណ្ឋាន មើលឃើញដឹងបានចំរើនស្មារតី
គេចផុតវាលភក់នរកអវិចី ឆ្លងផុតទុក្ខភ័យអាស្រ័យធម្មយាន។
ខ្ញុំសូមប្រកាសសច្ចវាចា ថាបុណ្យនេះណាកើតព្រោះធម្មទាន
ដែលធ្លាប់បានស្តាប់មកទាំងប៉ុន្មាន នាំចិត្តសន្តានឱ្យមានសទ្ធា។
សូមអនុមោទនាកុសល ឧទ្ទិសជូនផលដល់ញាតិគ្រប់គ្នា
មាតាបិតាគ្រូឧបជ្ឈាយ៍ បងប្អូនមីងមាញាតិគ្រប់សន្តាន។
សូមឱ្យបានសុខសិរីសួស្តី ផុតទុក្ខផុតភ័យរកស៊ីមានបាន
សូមបុណ្យដែលខ្ញុំធ្វើទាំងប៉ុន្មាន ជួយនាំរុញច្រានបានជួបធម៌ពិត។
បើមានគូគ្រងសូមគូដោយធម៌ បើមានកូន ព សូមជាបណ្ឌិត
សូមជួបតែញាតិជាកល្យាណមិត្ត សូមមានគំនិតគិតតែរឿងល្អ។
គ្រប់ជាតិសូមជួបតែផ្លូវមានប្លង់ បុណ្យជួយតម្រង់ទានតាមកំដរ
បើមានភ្លាំងភ្លាត់សីលស្រង់បន្ត សូមតោងព្រះធម៌លុះដល់និព្វាន។

(តទៅលេខក្រោយ)

# រាសីប្រចាំខែមិថុនា

**១.ឆ្នាំជូត:** រាសីខែនេះល្អមធ្យម។ ការប្រកបកិច្ចការងារពុំបានទទួលផលល្អឡើយ។ ចំណែកការធ្វើដំណើរត្រូវប្រយ័ត្នបន្តិចទើបបានសុខ។ រីឯការរស់នៅវិញ លោកអ្នកមានភាពប្តូរផ្លាស់ច្រើន ជូនកាលត្រូវរ៉ូវគ្នា ជួនកាលទាស់ទែងគ្នា។

**២.ឆ្នាំឆ្លូវ** រាសីខែនេះល្អមធ្យម។ ការប្រកបរបរជួញដូរមានភាពពុំសូវកាក់កបទេ។ ការធ្វើដំណើរផ្លូវឆ្ងាយប្រព្រឹត្តទៅជាធម្មតា តែត្រូវមានស្មារតីរឹងប៉ឹងកុំជឿសម្តីអ្នកដទៃខ្លាំងពេក។ជីវិតរស់នៅមានការមិនចុះសម្រុងនឹងគ្នាទេ។

**៣.ឆ្នាំខាល** រាសីខែនេះស្រុតចុះ។ ការប្រកបរបររកស៊ីផ្សេងៗទទួលផលជាមធ្យម។ ការធ្វើដំណើរកំសាន្តត្រូវមានការប្រុងប្រយ័ត្នខ្ពស់។រីឯជីវិតរស់នៅក្នុងសង្គមគ្រួសារវិញ មិនសូវមានភាពរុះរាយនិងយល់ចិត្តគ្នាទេ ហើយជួបការអាក់អន្លួលផ្លូវចិត្តច្រើន។

**៤.ឆ្នាំថោះ** រាសីខែនេះល្អមធ្យម។ រយៈពេលនេះ កិច្ចការងារណាដែលបំពេញខ្លួនឯងបានគួរខិតខំឲ្យអស់ពីកំលាំងកាយចិត្តនឹងទទួលបានផលល្អ។ ដំណើរចាកចេញក្រៅផ្ទះត្រូវប្រកាន់ចិត្តឲ្យនឹងធឹងមានគេព្យាបាទ តែពុំបានសំរេចទេ។ ចំពោះការរស់នៅមានដំណើរថយក្រោយច្រើន។

**៥.ឆ្នាំរោង** ដួងរាសីខែនេះខ្ពស់ត្រដែត។ បើជាអ្នកប្រកបរបររកស៊ីជួញដូរទទួលជោគជ័យច្រើន អាចប្រមូលបានផលគួរជាទីគាប់ចិត្ត។ ការធ្វើដំណើរជិតឆ្ងាយមានភាពសុខសាន្ត។ រីឯសេចក្តីស្នេហាវិញពុំសូវល្អទេ ច្រើនជួបបញ្ហាក្នុងសង្គមគ្រួសារ។

**៦.ឆ្នាំម្សាញ់** រាសីខែនេះល្អបង្គួរ។ ចំពោះការប្រកបរបរជួញដូរប្រាក់ចំណូលរកបានសមល្មម។ បើការចេញដំណើរផ្លូវឆ្ងាយត្រូវប្រុងប្រយ័ត្នបន្តិចក្រែងជួបគ្រោះថ្នាក់។ រីឯការរស់នៅក្នុងសង្គមគ្រួសារវិញ មានការអធ្យាស្រ័យគ្នាទៅវិញទៅមកបានច្រើន។

**៧.ឆ្នាំមមី** រាសីខែនេះល្អជាមធ្យម។លោកអ្នកប្រកបការងារពុំសូវទទួលផលល្អទេ បើចង់បោះទុនរកស៊ីត្រូវប្រយ័ត្នបន្តិចព្រោះមានការខាតបង់ច្រើន។ បញ្ហាសង្គមគ្រួសារវិញនោះមានដំណើរថយក្រោយបន្តិចនិងចាប់កំហុសគ្នាខ្លះៗ។

**៨.ឆ្នាំមមែ** រាសីខែនេះស្រុតចុះ។ ការជួញដូរផ្សេងៗប្រាក់ចំណូលមានការខ្សត់ខ្សោយបន្តិច ដូច្នេះលោកអ្នកត្រូវតែខិតខំប្រឹងប្រែង។ ចំពោះការធ្វើដំណើរវិញប្រយ័ត្នឧប្បត្តិហេតុយាយី។ ចំណែកការរស់នៅមានការខ្វល់ខ្វាយ ព្រោះតែគិតម្នាក់ឯងច្រើនពេក។

**៩.ឆ្នាំវក** ដួងរាសីខែនេះល្អមធ្យម។ ចំពោះលោកអ្នកប្រកបរបររកស៊ីទទួលបានផលល្អ។ ការធ្វើដំណើរផ្លូវឆ្ងាយពុំសូវមានសុវត្ថិភាពទេ ប្រយ័ត្នឧប្បត្តិហេតុកើតឡើង។ ចំណងអាពាហ៍ពិពាហ៍វិញនោះ មានការប្រែប្រួលមិនទៀងទាត់ទេ ត្រូវចេះអត់ឱនឱ្យគ្នាទៅវិញទៅមក។

**១០.ឆ្នាំរកា** រាសីខែនេះល្អបង្គួរ។ ដំណើរជីវិតប្រកបទៅមុខមិនមានការផ្លាស់ប្តូរទេ។ ចំពោះការប្រកបរបររកស៊ីជួញដូរមានភាពរស់រវើកឡើងវិញ ទទួលបានប្រាក់ចំណេញ សមគួរ។ចំពោះការរស់នៅមានដំណើរជឿនលឿនទៅមុខបង្គួរ។

**១១.ឆ្នាំច** រាសីខែនេះល្អជាមធ្យម។ ការធ្វើដំណើរចាកចេញទៅក្រៅផ្ទះលោកអ្នកមានសុវត្ថិភាពល្អញាតិមិត្តរាប់អាន។ រីឯការរកទទួលទានវិញគឺបានផលជាធម្មតា។ ចំណែកការរស់នៅលោកអ្នកនឹងមានសុភមង្គលល្អក្នុងសង្គមគ្រួសារ។

**១២.ឆ្នាំកុរ** រាសីខែនេះល្អបង្គួរ។ សំរាប់លោកអ្នកប្រកបរបររកស៊ីទទួលបានផលចំណេញគួរសម។ ការធ្វើដំណើរជិតឆ្ងាយគ្មានអ្វីជាឧបសគ្គទេតែត្រូវប្រយ័ត្នបន្តិច ។ចំណែកក្នុងរង្វង់គ្រួសារមានភាពរីកចំរើននិងជឿនលឿនទៅមុខ កំពុងបើកទំព័រជីវិតថ្មីសម្រាប់លោកអ្នកហើយ។

# រូបភាពសកម្មភាពនៅពេលបុណ្យវិសាខបូជា នៅវត្តខេមររង្សី ក្រុងសាន់ហូសេ រដ្ឋកាលីហ្វ័រញ៉ា



















